អគ្គលេខាធិការដ្ឋាន (ព្រឹទ្ធសភា)
ចូល
លេខ....០៩១....
ថ្ងៃទី..........ម៉ោង..........
បញ្ជូនទៅ..........

នស/រកម/១០០០/០៨

# ព្រះរាជក្រម

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជសារិទ្ធ ឧភតោសុជាតិ វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី០៨ ខែមីនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើជាផ្លូវការនូវច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៩០ ៩១ ៩៣និងមាត្រាទាំងឡាយនៃជំពូកទី៨ដល់ជំពូកទី១៤ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ខែកក្កដាឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំ អំពីសម្តេចនាយករដ្ឋមន្ត្រី និង អំពីទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពី ការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជា ចូលរួមក្នុងសន្ធិសញ្ញាស្តីពីការហាមឃាត់ជាទូទៅនៃការសាកល្បងអាវុធនុយក្លេអ៊ែរ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃ ទី ៨ ខែ សីហា ឆ្នាំ ២០០០ នាសម័យប្រជុំពេញអង្គលើកទី ៤ នីតិកាលទី ២ ហើយដែលព្រឹទ្ធសភាបានអនុម័តយល់ស្របតាមលើទំរង់ និង គតិនៃច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០០០ នាសម័យប្រជុំពេញអង្គលើក ទី ៣ នីតិកាលទី ១ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖

# ច្បាប់

## ស្តីពី

## ការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជា ចូលរួមក្នុង
## សន្ធិសញ្ញាស្តីពីការហាមឃាត់ជាទូទៅ នៃការសាកល្បងអាវុធនុយក្លេអ៊ែរ

**មាត្រា ១.-**

អនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជា ចូលរួមក្នុងសន្ធិសញ្ញាស្តីពីការហាមឃាត់ជាទូទៅនៃការសាកល្បងអាវុធនុយក្លេអ៊ែរ ដែលចុះហត្ថលេខានៅថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៦ ក្នុងឱកាសមហាសន្និបាតនៃអង្គការសហប្រជាជាតិ នាទីក្រុងញូវយ៉ក ។

**មាត្រា ២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តនូវសន្ធិសញ្ញានេះ ។

រាជធានីភ្នំពេញថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ២០០០

**ព្រះហស្តលេខា**

**នរោត្តម សីហនុ**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

ហត្ថលេខា

ហ៊ុន សែន

បានជំរាបជូន សម្តេចនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិស្តីទី

**ហត្ថលេខា**

**អ៊ុច គឹមអន**

លេខ : ១៩០ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញថ្ងៃទី ១៦ ខែ[illegible] ឆ្នាំ២០០០

អគ្គលេខាធិការរាជរដ្ឋាភិបាល

# សន្ធិសញ្ញា

# ស្តីពី

# ការហាមឃាត់ជាដាច់ខាត នៃការសាកល្បងអាវុធនុយក្លេអ៊ែរ

*********

## បុព្វកថា

រដ្ឋទាំងឡាយដែលជាភាគីនៃសន្ធិសញ្ញា ដែលតទៅនេះកំណត់ហៅថា រដ្ឋភាគីសន្ធិសញ្ញា

-សូមស្វាគមន៍ ចំពោះកិច្ចព្រមព្រៀងអន្តរជាតិនានា និងវិធានការវិជ្ជមានដ៏ទៃទៀត នាឆ្នាំចុងក្រោយថ្មីៗនេះ លើវិស័យកាត់បន្ថយសព្វាវុធនុយក្លេអ៊ែរ រួមមានទាំងការកាត់បន្ថយកន្លែងផលិតអាវុធនុយក្លេអ៊ែរ ( arsenals of nuclear weapons ) និងការការពារនូវការសាយភាយអាវុធនុយក្លេអ៊ែរគ្រប់ទិដ្ឋភាពផងដែរ ។

-ដោយយល់ឃើញ ពីសារៈសំខាន់នៃការអនុវត្តន៍អោយបានពេញលេញ និងឱ្យបានឆាប់រហ័សនូវកិច្ចព្រមព្រៀង និងវិធានការទាំងឡាយនេះ ។

-ដោយជឿជាក់ថា សភាពការណ៏អន្តរជាតិនាពេលបច្ចុប្បន្ន គឺជាពេលវេលាតំរូវអោយមានវិធានការបន្ថែមដ៏មានប្រសិទ្ធិភាព ឆ្ពោះទៅរកការរំសាយសព្វាវុធនុយក្លេអ៊ែរ និងប្រឆាំងចំពោះការសាយភាយអាវុធនុយក្លេអ៊ែរ ក្នុងគ្រប់ទិដ្ឋភាពទាំងអស់ និងដោយមានការប្រកាសពីគោលបំណងរបស់ខ្លួន ក្នុងការអនុវត្តន៏វិធានការបែបនេះផងដែរ ។

-ដោយបញ្ជាក់នូវភាពចាំបាច់ ដើម្បីបន្តការប្រឹងប្រែងអោយមានការវិវឌ្ឍន៍ និងឱ្យមានប្រព័ន្ធត្រឹមត្រូវក្នុងការកាត់បន្ថយអាវុធនុយក្លេអ៊ែរទូទាំងពិភពលោក និងឈានដល់ទីបញ្ចប់នៃការកំចាត់ចោលទាំងស្រុងនៃអាវុធទាំងនោះ និងការរំសាយជាទូទៅនិងទាំងស្រុង ក្រោមការត្រួតពិនិត្យជាអន្តរជាតិយ៉ាងម៉ត់ចត់ និងប្រកបដោយប្រសិទ្ធិភាព ។

-ដោយទទួលស្គាល់ថា ការបញ្ចប់នូវការសាកល្បងនូវការផ្ទុះអាវុធនុយក្លេអ៊ែរ និងជាតិផ្ទុះនុយក្លេអ៊ែរដ៏ទៃទៀត ដោយកំរិតការអភិវឌ្ឍន៏ និងការធ្វើឱ្យកាន់តែប្រសើរនូវគុណភាពនៃអាវុធនុយ-

ក្លែអែរ និងការបញ្ឈប់នូវការអភិវឌ្ឍន៍ ក្នុងការធ្វើអោយមានប្រភេទថ្មីទៀតនៃអាវុធនុយក្លេអែរ និងបង្កើតបានជាវិធានការដ៏មានប្រសិទ្ធភាពមួយចំពោះការរំសាយអាវុធនុយក្លេអែរ និងការមិនសាយភាយនូវគ្រប់ទិដ្ឋភាពនៃអាវុធនេះ ។

-ដោយទទួលស្គាល់បន្ថែមទៀតថា ការបញ្ឈប់នូវការផ្ទុះនុយក្លេអែរគ្រប់បែបយ៉ាងទាំងអស់នោះគឺជាជំហានដ៏មានន័យមួយក្នុងការធ្វើអោយបានសំរេចនូវដំណើរការជាប្រព័ន្ធ ដើម្បីទទួលបាននូវការរំសាយអាវុធនុយក្លេអែរទាំងស្រុង ។

-ដោយជឿជាក់ថា មធ្យោបាយដ៏មានប្រសិទ្ធិភាពបំផុត ដើម្បីទទួលបានលទ្ធផលក្នុងការបញ្ឈប់នូវការសាកល្បងអាវុធនុយក្លេអែរនោះ គឺការចុះសន្ធិសញ្ញាមួយ ស្តីពីការហាមប្រាមជាទូទៅនូវការសាកល្បងអាវុធនុយក្លេអែរ ដែលសន្ធិសញ្ញានោះមានលក្ខណៈជាសកល និងអន្តរជាតិប្រកបដោយការផ្ទៀងផ្ទាត់ដ៏មានប្រសិទ្ធភាព ។ សន្ធិសញ្ញានេះ គឺជាគោលបំណងអាទិភាពខ្ពស់បំផុត របស់សហគមន៍អន្តរជាតិលើវិស័យរំសាយ និងមិនឱ្យសាយភាយអាវុធនុនេះ ។

-ដោយកត់សំគាល់ពីគោលបំណងរបស់ភាគី នៃសន្ធិសញ្ញា ឆ្នាំ ១៩៦៣ ស្តីពីការហាមប្រាមការសាកល្បងអាវុធនុយក្លេអែរ នៅក្នុងបរិយាកាស ក្រៅលំហអាកាស និងក្រោមទឹក ដើម្បីសំរេចបានលទ្ធផលនូវការបញ្ឈប់ទាំងស្រុង នៃការសាកល្បងការផ្ទុះអាវុធនុយក្លេអែរ ជារៀងរហូត ។

-ដោយកត់សំគាល់ផងដែរ នូវទស្សនៈទាំងឡាយ ដែលបានសំដែងថា សន្ធិសញ្ញានេះ អាចជួយរួមចំណែកក្នុងការការពារបរិស្ថានផងដែរ ។

-ដោយបញ្ជាក់ពីគោលបំណង ដែលទាក់ទាញអោយរដ្ឋទាំងអស់ចូលជាភាគីនៃសន្ធិសញ្ញានេះ និង ទិសដៅចូលរួមជាវិភាគទានប្រកបដោយប្រសិទ្ធិភាព ដើម្បីការពារនៃការសាយភាយអាវុធនុយក្លេអែរគ្រប់ទិដ្ឋភាព និងជាដំណើរឆ្ពោះទៅរកការរំសាយអាវុធនុយក្លេអែរ ដែលជាហេតុនាំអោយមានការកាន់តែប្រសើរ នូវសន្តិសុខ និងសន្តិភាពអន្តរជាតិផងដែរ ។

បានយល់ព្រមគ្នាដូចតទៅ :

# មាត្រាទី ១
# កាតព្វកិច្ចជាមូលដ្ឋាន

១-រដ្ឋភាគីនីមួយៗធានាថា មិនអនុវត្តនូវការសាកល្បងនូវការផ្ទុះអាវុធនុយក្លេអ៊ែរ ឬការផ្ទុះសារធាតុនុយក្លេអ៊ែរផ្សេងៗទៀតឡើយ ហើយហាមឃាត់ និងការពារមិនអោយមានការផ្ទុះសារធាតុនុយក្លេអ៊ែរបែបនេះ កើតមាននៅកន្លែងណាមួយ ដែលស្ថិតនៅក្រោមយុត្តាធិការ ឬសមត្ថកិច្ចរបស់ខ្លួនឡើយ ។

២-រដ្ឋភាគីនីមួយៗសន្យាបន្ថែមទៀតថា មិនត្រូវអនុវត្តនូវអ្វីដែលជាមូលហេតុ ឬការជំរុញអោយមានការសាកល្បងការផ្ទុះអាវុធនុយក្លេអ៊ែរ ឬការផ្ទុះសារធាតុនុយក្លេអ៊ែរផ្សេងៗទៀតណាមួយឡើយ ។

# មាត្រាទី ២
# អង្គការចាត់តាំង
## ក-បទបញ្ញត្តិទូទៅ

១-ដោយហេតុនេះ រដ្ឋភាគីទាំងអស់ នឹងបង្កើតអង្គការសន្ធិសញ្ញា ស្តីពីការហាមប្រាមជាទូទៅនៃការសាកល្បងអាវុធនុយក្លេអ៊ែរ ដែលអំណើះតទៅហៅថា (( អង្គការ )) ដើម្បីសំរេចបាននូវទិសដៅ និងគោលបំណងនៃសន្ធិសញ្ញានេះ និងដើម្បីធានាការអនុវត្តន៍បទបញ្ញត្តិនៃសន្ធិសញ្ញារួមទាំងការផ្ទៀងផ្ទាត់ជាអន្តរជាតិ លើការអនុវត្តន៍ស្របតាមសន្ធិសញ្ញា និងដើម្បីផ្តល់ជាវេទិកាសំរាប់ពិភាក្សា និងសហប្រតិបត្តិការរវាងរដ្ឋភាគីទាំងអស់ ។

២-រដ្ឋភាគីទាំងអស់ គឺជាសមាជិករបស់អង្គការនេះ ។ គ្មានរដ្ឋជាភាគីណាមួយដែលត្រូវគេដកហូតសមាជិកភាពរបស់ខ្លួន ពីអង្គការនេះឡើយ ។

៣-ទីស្នាក់ការនៃអង្គការស្ថិតនៅទីក្រុងវៀន សាធារណរដ្ឋអូទ្រីស ។

៤-តាមរយៈអង្គការនេះ នឹងមានបង្កើតជាអង្គការចាត់តាំងនានា ដូចជាសន្និសីទរដ្ឋជាភាគីទាំងអស់ ក្រុមប្រឹក្សាប្រតិបត្តិ និងលេខាធិការដ្ឋានបច្ចេកទេស ដែលរួមមានទាំងមជ្ឈមណ្ឌលទិន្នន័យអន្តរជាតិផងដែរ ។

៥-រដ្ឋជាភាគីនីមួយៗ នឹងសហការជាមួយអង្គការ ក្នុងការអនុវត្តន៍មុខងាររបស់អង្គការស្របតាមសន្ធិសញ្ញានេះ ។ រដ្ឋជាភាគី នឹងពិភាក្សាជាមួយគ្នាដោយផ្ទាល់ ឬក៏តាមរយៈអង្គការ ឬក៏តាម

នីតិវិធីអន្តរជាតិផ្សេងៗទៀត រួមមាន នីតិវិធីដែលមានចែងក្នុងក្របខណ្ឌអង្គការសហប្រជាជាតិ និងស្របតាមធម្មនុញ្ញអង្គការសហប្រជាជាតិ លើបញ្ហាណាមួយដែលអាចលើកឡើងទាក់ទងនឹងកម្មវត្ថុ និងគោលបំណង ឬការអនុវត្តនីបទបញ្ញត្តិនានានៃសន្ធិសញ្ញានេះ ។

៦-អង្គការអនុវត្តការផ្ទៀងផ្ទាត់សកម្មភាពនានា ដែលមានចែងក្នុងសន្ធិសញ្ញាតាមរបៀប ដើម្បីសំរេចបានតាមពេលវេលាសមស្រប និងប្រកបដោយប្រសិទ្ធិភាពនូវបំណងទាំងនេះ ។ អង្គការស្នើសុំតែពត៌មាន និងទិន្នន័យសំខាន់ៗ ដើម្បីបំពេញការទទួលខុសត្រូវរបស់ខ្លួនតាមសន្ធិសញ្ញានេះ ។ អង្គការអនុវត្តដោយប្រុងប្រយ័ត្នក្នុងការការពារព័តមានសំងាត់ ស្តីពីសកម្មភាពស៊ីវិល និងយោធា ដែលអង្គការបានដឹងតាមរយៈការអនុវត្តនីសន្ធិសញ្ញានេះ ជាពិសេសត្រូវប្រព្រឹត្តិតាមបទបញ្ញត្តិរក្សាការសំងាត់នានា ដែលចែងក្នុងសន្ធិសញ្ញា ។

៧-រដ្ឋភាគីនីមួយៗ ត្រូវបានរក្សាទុកជាសំងាត់ និងលៃលកប្រើប្រាស់យ៉ាងពិសេសនូវព័តមានដែលខ្លួនបានទទួលជាសំងាត់ពីអង្គការទាក់ទងនឹងការអនុវត្តនីសន្ធិសញ្ញានេះ ។ រដ្ឋនីមួយៗត្រូវរក្សាពត៌មាន និងទិន្នន័យបែបនេះ ទៅតាមសិទ្ធិនិងកាតព្វកិច្ចរបស់ខ្លួន ដែលមានចែងក្នុងសន្ធិសញ្ញា ។

៨-អង្គការនេះ ដែលជាអង្គការឯករាជ្យត្រូវស្វែងយល់ពីអត្ថប្រយោជន៍ នូវបទពិសោធន៍ដែលមានកន្លងមក និងជួយសំរួល ដោយការវាយតម្លៃសមរម្យ និងខ្ពស់បំផុតទៅតាមរយៈនៃការសំរបសំរួលកិច្ចសហការជាមួយនឹងអង្គការអន្តជាតិផ្សេងៗទៀត ដូចជាអង្គការអន្តរជាតិថាមពលបរិមាណូជាដើម ។ ដោយមិនរួមបញ្ចូលនូវកិច្ចសន្យាដែលមានលក្ខណៈពាណិជ្ជកម្មធុនតូច ឬធម្មតា ការសំរបសំរួលបែបនេះត្រូវធ្វើជាកិច្ចព្រមព្រៀង ដើម្បីដាក់សុំការយល់ព្រមនៅក្នុងសន្និសីទនៃរដ្ឋភាគីទាំងអស់ ។

៩-យោងទៅតាមកំរិតនៃការវាយតម្លៃរបស់អង្គការសហប្រជាជាតិ ការចំណាយសំរាប់សកម្មភាពរបស់អង្គការ នឹងត្រូវបានកំណត់ជារៀងរាល់ឆ្នាំ ដោយរដ្ឋភាគីទាំងអស់ ស្របតាមមាត្រដ្ឋានកំណត់របស់សហប្រជាជាតិ ដោយសំរបសំរួលតាមភាពខុសគ្នានៃសមាជិកភាពរវាងសហប្រជាជាតិ និងអង្គការនេះ ។

១០-វិភាគទានទាំងឡាយរបស់រដ្ឋភាគីទាំងអស់ ចំពោះគណៈកម្មការរៀបចំអង្គការត្រូវដកចេញពីវិភាគទានរបស់សមាជិក បង់សំរាប់ថវិកាអង្គការតាមវិធីសមរម្យមួយ ។

១១-សមាជិកមួយនៃអង្គការដែលមិនបានបង់វិភាគទានរបស់ខ្លួន តាមពេលកាលកំណត់នោះ នឹងមិនមានសិទ្ធិបោះឆ្នោតក្នុងអង្គការ ប្រសិនបើចំនួនប្រាក់ដែលមិនបានបង់នោះ ស្មើឬលើសវិភាគទានរយៈពេល ២ ឆ្នាំ ឡើងទៅ ។ ប៉ុន្តែសន្និសីទ របស់រដ្ឋជាភាគីទាំងអស់ អាច

អនុញ្ញាតិអោយសមាជិកបែបនេះបោះឆ្នោត ប្រសិនបើសមាជិកនោះមិនបានបង់វិភាគទានដោយសារហួសពីសមត្ថកិច្ចដែលខ្លួនមាន ។

## ខ_សន្និសីទនៃរដ្ឋជាភាគី
## សមាសភាព នីតិវិធី និង ការធ្វើសេចក្តីសំរេចចិត្ត

១២-សន្និសីទនៃរដ្ឋជាភាគីទាំងអស់ ដែលចាប់ពីពេលនេះទៅហៅថា << សន្និសីទ >> ដែលនឹងត្រូវចូលរួមដោយសមាជិករដ្ឋជាភាគីទាំងអស់ ។ រដ្ឋភាគីនីមួយៗត្រូវមានតំណាងម្នាក់ចូលរួមក្នុងសន្និសីទ ហើយអាចអមដោយតំណាងរង និងទីប្រឹក្សា ។

១៣-សម័យប្រជុំដំបូងនៃសន្និសីទ នឹងត្រូវបានកោះប្រជុំដោយប្រទេសដែលតំកល់សន្និសញ្ញានេះ ដោយមិនអោយលើសពីចំនួន ៣០ ថ្ងៃ បន្ទាប់ពីការចូលជាធរមាននៃសន្និសញ្ញានេះ ។

១៤-សន្និសីទ នឹងមានការប្រជុំដែលប្រារព្ធឡើងជារៀងរាល់ឆ្នាំ ប្រសិនបើគ្មានការសំរេចចិត្តណាផ្សេងទៀតនោះ ។

១៥-សម័យប្រជុំពិសេស នៃសន្និសីទនឹងត្រូវបានកោះប្រជុំ ក្នុងករណី :

ក-នៅពេលមានសេចក្តីសំរេចពីសន្និសីទយ៉ាងដូច្នេះ

ខ-នៅពេលមានការស្នើសុំពីក្រុមប្រឹក្សាប្រតិបត្តិ ឬ

គ-មានការស្នើសុំពីរដ្ឋជាភាគីណាមួយ ដោយមានការគាំទ្រពីមតិភាគច្រើននៃរដ្ឋជាភាគី។

សម័យប្រជុំពិសេសនោះ នឹងត្រូវបានកោះប្រជុំមិនអោយលើសពីចំនួន ៣០ ថ្ងៃ បន្ទាប់ពីមានសេចក្តីសំរេចរបស់អង្គសន្និសីទ ឬការស្នើសុំរបស់ក្រុមប្រឹក្សាប្រតិបត្តិ ឬការសំរេចដែលមានការគាំទ្រដ៏ចាំបាច់ លើកលែងតែមានសេចក្តីសំរេច ឬការស្នើសុំបែបបទពិសេសណាមួយផ្សេងទៀត ។

១៦-ដោយអនុលោមតាមមាត្រាទី ៧ សន្និសីទក៏អាចកោះប្រជុំក្នុងបែបបទសន្និសីទវិសោធនកម្មផងដែរ ។

១៧-ដោយអនុលោមតាមមាត្រាទី ៨ សន្និសីទក៏អាចកោះប្រជុំ ក្នុងបែបបទសន្និសីទពិនិត្យឡើងវិញផងដែរ ។

១៨-សម័យប្រជុំ នឹងប្រព្រឹត្តិឡើងនៅឯទីស្នាក់ការរបស់អង្គការ លើកណាសន្និសីទមិនបានសំរេចចិត្តផ្សេងពីនេះទៀត ។

១៩-សន្និសីទ ., នឹងអនុម័តយល់ព្រមនូវបទបញ្ញត្តិទាំងឡាយនៃនីតិវិធី ។ នៅពេលចាប់ផ្ដើមសម័យប្រជុំនីមួយៗ ត្រូវមានការបោះឆ្នោតជ្រើសរើសប្រធាន និងមន្ត្រីសមាជិកដ៏ទៃផ្សេងទៀតរបស់អង្គប្រជុំ ។ ពួកគេនឹងទទួលតំណែងនេះ រហូតដល់មានប្រធានថ្មី និងសមាជិកថ្មីដ៏ទៃទៀត ដែលត្រូវបានបោះឆ្នោត នៅសម័យប្រជុំបន្ទាប់ ។

២០-កូរ៉ុមនៃការប្រជុំ គឺចំនួនភាគច្រើននៃរដ្ឋជាភាគី ។

២១-រដ្ឋជាភាគីនីមួយៗ មានសំលេងមួយ ។

២២-សន្និសីទ នឹងយកការសំរេចចិត្ត ស្ដីពីបញ្ហានៃនីតិវិធីតាមមតិភាគច្រើនរបស់សមាជិក ដែលមានវត្តមាន និងបានបោះឆ្នោត ។ សេចក្ដីសំរេចចិត្តពីបញ្ហាសំខាន់ នឹងត្រូវបានយកតាមមតិឯកភាពកុងសង់ស៊ុស ( Consensus ) ដែលអាចធ្វើបាន ។ ប្រសិនបើ មតិឯកភាពកុងសង់ស៊ុស ( Consensus ). មិនអាចសំរេចទៅបានទេនោះ ពេលដែលត្រូវសំរេចលើរឿងអ្វីមួយ ប្រធាននៃសន្និសីទ នឹងពន្យារពេលបោះឆ្នោតរយៈពេល ២៤ ម៉ោង ហើយស្ថិតក្នុងកំឡុងពេលនៃការពន្យារពេលនោះ ត្រូវខិតខំប្រឹងប្រែងឱ្យកាន់តែខ្លាំងឡើង ដើម្បីសំរួលដល់ការសំរេចមតិឯកភាពកុងសង់ស៊ុស ( Consensus ) ហើយនឹងរាយការណ៍ប្រាប់ដល់អង្គសន្និសីទនៅមុនពេលបញ្ចប់នៃរយៈពេលនោះ ។ ប្រសិនបើមតិឯកភាពកុងសង់ស៊ុស ( Consensus ) មិនអាចនឹងរកបានក្នុងរយៈពេល ២៤ ម៉ោងនេះទេ សន្និសីទនឹងអនុម័តយកសេចក្ដីសំរេចចិត្តតាមមតិភាគច្រើន ២/៣ នៃចំនួនសមាជិក ដែលមានវត្តមាន និងបានបោះឆ្នោត លើកលែងតែនៅក្នុងសន្ធិសញ្ញានេះ មិនមានបញ្ជាក់តាមបែបបទផ្សេង ។ នៅពេលមានរឿងកើតឡើង ថាតើបញ្ហាមួយជាបញ្ហាសំខាន់ ឬមិនសំខាន់បញ្ហានោះ ត្រូវបានចាត់ទុកជាបញ្ហាសំខាន់ លើកលែងតែណាមិនមានការសំរេចចិត្តផ្សេងពីនេះ ដោយមតិភាគច្រើនទាមទារ ។

២៣-នៅពេលអនុវត្តមុខងារតាមកថាខ័ណ្ឌទី ២៦ ( ជ ) សន្និសីទនឹងយកការសំរេចមួយ ដើម្បីបន្ថែមរដ្ឋណាមួយចូលទៅក្នុងបញ្ជីនៃរដ្ឋទាំងឡាយដែលមាននៅក្នុងឧបសម្ព័ន្ធទី ១ នៃសន្ធិសញ្ញានេះដោយអនុលោមតាមនីតិវិធីសំរាប់សេចក្ដីសំរេច ស្ដីពីបញ្ហាសំខាន់មានកំណត់នៅក្នុងកថាខ័ណ្ឌទី ២២ ។ ដោយមិនបំពារបំពានកថាខ័ណ្ឌទី ២២ សន្និសីទនឹងសំរេចលើការកែប្រែឧបសម្ព័ន្ធទី ១ នៃសន្ធិសញ្ញានេះ តាមមតិឯកភាពកុងសង់ស៊ុស ( Consensus ) ។

## អំណាច និង តួនាទី

២៤-សន្និសីទ គឺជាស្ថាប័នគ្រឹះរបស់អង្គការ ។ សន្និសីទនឹងពិនិត្យ ពិចារណាលើសំណួររឿងរ៉ាវ ឬបញ្ហានានាក្នុងក្របខ័ណ្ឌសន្ធិសញ្ញានេះ រួមបញ្ចូលទាំងសំណួរទាំងឡាយទាក់ទងនឹងអំណាច

និងតួនាទីនៃក្រុមប្រឹក្សាប្រតិបត្តិ និងលេខាធិការដ្ឋានបច្ចេកទេស ។ សន្និសីទអាចចេញជាអនុសាសន៍ និងសេចក្តីសំរេចចិត្តស្តីពីសំណួររឿងរ៉ាវ ឬបញ្ហានានាក្នុងក្របខ័ណ្ឌនៃសន្ធិសញ្ញានេះ ដែលបានលើកឡើងដោយរដ្ឋជាភាគី ឬដោយក្រុមប្រឹក្សាប្រតិបត្តិ ។

២៥-សន្និសីទនឹងត្រួតពិនិត្យមើលដល់ការអនុវត្តន៍នៃសន្ធិសញ្ញានេះ និងសកម្មភាព ដើម្បីជំរុញអោយដល់គោលដៅ និងបំណងរបស់វារួមទាំងការពិនិត្យឡើងវិញ ចំពោះការប្រព្រឹត្តិតាមសន្ធិសញ្ញានេះ ។ សន្និសីទត្រួតពិនិត្យមើលផងដែរ នូវរាល់សកម្មភាពនៃក្រុមប្រឹក្សាប្រតិបត្តិ និងលេខាធិការដ្ឋានបច្ចេកទេស ហើយអាចចេញនូវគោលការណ៍ណែនាំណាមួយរបស់ពួកគេ ដើម្បីហ្វឹកហាត់ដល់តួនាទីរបស់ពួកគេ ។

២៦-សន្និសីទត្រូវ :

ក-ពិនិត្យពិចារណា និងអនុម័តនូវរបាយការណ៍របស់អង្គការ ស្តីពីការអនុវត្តន៍នៃសន្ធិសញ្ញានេះ និងកម្មវិធីនៃការរៀបចំចាត់ចែងថវិកាប្រចាំឆ្នាំរបស់អង្គការ ដែលបានដាក់ជូនសន្និសីទ ដោយក្រុមប្រឹក្សាប្រតិបត្តិព្រមទាំងធ្វើការពិចារណាលើរបាយការណ៍ផ្សេងៗទៀត ។

ខ-សំរេចទៅលើកំរិតមាត្រដ្ឋាននៃវិភាគទានហិរញ្ញវត្ថុ ដែលត្រូវបានបង់ដោយរដ្ឋជាភាគីទាំងឡាយស្របតាមតាមកថាខ័ណ្ឌទី ៩ ។

គ-ធ្វើការបោះឆ្នោតជ្រើសរើសសមាជិកនៃក្រុមប្រឹក្សាប្រតិបត្តិ ។

ឃ-តែងតាំងអគ្គនាយកនៃលេខាធិការដ្ឋានបច្ចេកទេស (តទៅនេះហៅថាអគ្គនាយក )។

ង-ពិនិត្យ និងអនុមត័នូវបទបញ្ញត្តិនានានៃនីតិវិធីនៃក្រុមប្រឹក្សាប្រតិបត្តិ ដែលដាក់ជូនពិនិត្យដោយក្រុមប្រឹក្សានោះ ។

ច-ពិចារណា និងពិនិត្យឡើងវិញលើផ្នែកអភិវឌ្ឍន៍វិទ្យាសាស្ត្រនិងបច្ចេកវិទ្យា ដែលអាចមានឥទ្ធិពលដល់ការអនុវត្តន៍ប្រតិបត្តិនៃសន្ធិសញ្ញានេះ ។ នៅក្នុងន័យនេះ សន្និសីទអាចដឹកនាំដោយអគ្គនាយក ដើម្បីបង្កើតគណៈទីប្រឹក្សាវិទ្យាសាស្ត្រមួយ ( Scientific Advisory Board ) ដែលអាចជួយដល់ខ្លួនបានសំរាប់ការបំពេញតួនាទីរបស់ខ្លួនក្នុងការផ្តល់នូវមតិណែនាំផ្នែកឯកទេសនៅក្នុងវិស័យវិទ្យាសាស្ត្រ និងបច្ចេកទេសដែលមានពាក់ព័ន្ធនឹងសន្ធិសញ្ញានេះ ដល់សន្និសីទ ដល់ក្រុមប្រឹក្សាប្រតិបត្តិ ឬដល់រដ្ឋជាភាគីទាំងឡាយ ។ ក្នុងករណីនេះ គណៈទីប្រឹក្សាវិទ្យាសាស្ត្រ ត្រូវបានទទួលនូវភាពឯករាជ្យ ដល់ការបំពេការងារតាមលទ្ធភាព របស់គេរៀងៗខ្លួន និងបានជ្រើសតាំងដោយអនុលោមទៅតាមភារៈកិច្ចរបស់ពួកគេ ដែលបានអនុម័តយល់ព្រមដោយសន្និសីទដោយឈរលើមូលដ្ឋានជំនាញ និងបទពិសោធន៍របស់ពួកគេ ជាពិសេសវិស័យវិទ្យាសាស្ត្រ ដែលទាក់ទងចំពោះការអនុវត្តន៍សន្ធិសញ្ញានេះ ។

ឆ-ចាត់វិធានការចាំបាច់នានា ដើម្បីធ្វើឱ្យប្រាកដប្រជានូវរាល់ការអនុវត្តនៃសន្ធិសញ្ញានេះ និងធ្វើការកែសំរួល និងដោះស្រាយឡើងវិញនូវរាល់ស្ថានភាពណា ដែលមានលក្ខណៈផ្ទុយទៅនឹងសន្ធិសញ្ញានេះដោយអនុលោមតាមមាត្រាទី ៥ ។

ជ-ពិនិត្យពិចារណា និងយល់ព្រម នៅឯសម័យប្រជុំជាលើកដំបូងរបស់ខ្លួននូវសេចក្តីព្រាងកិច្ចព្រមព្រៀង ការសំរបសំរួលលក្ខខ័ណ្ឌនីតិវិធីឯកសារការងារប្រតិបត្តិគោលការណ៍ណែនាំទាំងឡាយ និងឯកសារអភិវឌ្ឍន៍ផ្សេងៗទៀត ដែលត្រូវរៀបចំនិងណែនាំដោយគណៈកម្មការបំរុង ។

ឈ-ពិនិត្យពិចារណា និងអនុម័តកិច្ចព្រមព្រៀងឬការសំរបសំរួល ដែលចរចាដោយលេខាធិការដ្ឋានបច្ចេកទេសជាមួយរដ្ឋជាភាគីទាំងឡាយ ឬរដ្ឋផ្សេងដទៃទៀត ក៏ដូចជាអង្គការអន្តរជាតិនានា ដែលនឹងចុះហត្ថលេខាដោយក្រុមប្រឹក្សាប្រតិបត្តិក្នុងនាមនៃអង្គការដោយអនុលោមតាមកថាខណ្ឌទី ៣៨ ( ជ ) ។

ញ-បង្កើតនូវសាខា ដែលសន្និសីទយល់ថាចាំបាច់ចំពោះការអនុវត្តន៍នូវតួនាទីរបស់ខ្លួនស្របតាមសន្ធិសញ្ញានេះ និង

ដ-កែសំរួលឧបសម្ព័ន្ធទី ១ នៃសន្ធិសញ្ញានេះដោយអនុលោមតាមកថាខណ្ឌទី ២៣ ។

## គ-ក្រុមប្រឹក្សាប្រតិបត្តិ
## សមាសភាព នីតិវិធី និង ការធ្វើសេចក្តីសំរេច

២៧-ក្រុមប្រឹក្សាប្រតិបត្តិមានសមាជិកចំនួន ៥១ នាក់ ។ រដ្ឋជាភាគីនីមួយៗនឹងមានសិទ្ធិបំពេញការងារដល់ក្រុមប្រឹក្សាប្រតិបត្តិស្របតាមបទបញ្ញត្តិ ដែលមានចែងក្នុងមាត្រានេះ ។

២៨-សមាសភាពនៃក្រុមប្រឹក្សាប្រតិបត្តិត្រូវកំណត់តាមភាពចាំបាច់ ក្នុងការបែងចែកអោយបានសមស្របទៅតាមលក្ខណៈភូមិសាស្ត្រ ដូចតទៅ :

ក-រដ្ឋជាភាគីចំនួន ១០ មកពីអាហ្វ្រិក

ខ-រដ្ឋជាភាគីចំនួន ៧ មកពីអឺរ៉ុបខាងកើត

គ-រដ្ឋជាភាគីចំនួន៩មកពីអាមេរិកឡាទីន និងប្រទេសនៅសមុទ្រការ៉ាអ៊ីប (Caribbean) ។

ឃ-រដ្ឋជាភាគីចំនួន ៧ មកពីមជ្ឈិមបូព៌ា និងអាស៊ីខាងត្បូង

ង-រដ្ឋជាភាគីចំនួន ១០ មកពីអាមេរិកខាងជើង និងអឺរ៉ុបខាងលិច និង

ច-រដ្ឋជាភាគីចំនួន ៨ មកពីអាស៊ីអាគ្នេយ៍ តំបន់ប៉ាស៊ីហ្វិក និងចុងបូព៌ា ។

គ្រប់រដ្ឋទាំងអស់ក្នុងចំណោមតំបន់ភូមិសាស្ត្រនីមួយៗខាងលើ ត្រូវធ្វើជាតារាងបញ្ជីនៅក្នុងឧបសម្ព័ន្ធទី ១ នៃសន្ធិសញ្ញានេះ ។ ឧបសម្ព័ន្ធទី ១ នៃសន្ធិសញ្ញានេះ នឹងត្រូវបានកែសម្រួលដោយសន្និសីទស្របតាមកថាខ័ណ្ឌទី ២៣ និង ២៦ ( ជ ) ។ កិច្ចការនេះ មិនមែនជាប្រធានបទសំរាប់ការធ្វើវិសោធនកម្ម ឬកែប្រែតាមនីតិវិធី ដែលមានចែងនៅក្នុងមាត្រាទី ៧ នោះឡើយ ។

២៩-សមាជិកនៃក្រុមប្រឹក្សាប្រតិបត្តិនឹងត្រូវបានជ្រើសរើសដោយសន្និសីទ ។ ក្នុងន័យនេះ តំបន់ភូមិសាស្ត្រនីមួយៗ ត្រូវកំណត់រដ្ឋជាភាគីដែលមកពីតំបន់នោះ ដើម្បីបោះឆ្នោតជ្រើសរើសជាសមាជិកនៃក្រុមប្រឹក្សាប្រតិបត្តិដូចតទៅ :

ក/ យ៉ាងហោចណាស់ចំនួន ១/៣ នៃចំនួនអាសនៈសំរាប់តំបន់ភូមិសាស្ត្រនីមួយៗ ត្រូវបានបំពេញដោយរដ្ឋជាភាគីក្នុងតំបន់នោះ តាមការគិតគូរដល់ផលប្រយោជន៍ផ្នែកសន្តិសុខ និងនយោបាយ ឈរលើមូលដ្ឋានសមត្ថភាពអាវុធនុយក្លេអ៊ែរ ដែលទាក់ទងចំពោះសន្ធិសញ្ញាហើយកំណត់ដោយទិន្នន័យអន្តរជាតិ ក៏ដូចជាបង្ហាញពីលក្ខណៈវិនិច្ឆ័យដើម្បីកំណត់អាទិភាពតាមតំបន់នីមួយៗ ដូចតទៅ:

១-ចំនួនឧបករណ៍ត្រួតពិនិត្យការផ្សាយនៃប្រពន្ធ័ត្រួតពិនិត្យអន្តរជាតិ ។

២-ជំនាញ និងបទពិសោធន៍ក្នុងការប្រើប្រាស់បច្ចេកវិទ្យាត្រួតពិនិត្យ ។

៣-វិភាគទានថវិកាប្រចាំឆ្នាំរបស់អង្គការ ។

ខ/ អាសនៈមួយក្នុងចំណោមអាសនៈនៃតំបន់ភូមិសាស្ត្រនីមួយៗ ត្រូវបំពេញនៅលើមូលដ្ឋានប្តូរវេនគ្នាដោយរដ្ឋជាភាគី ដែលស្ថិតនៅមុនគេ ទៅតាមលំដាប់តួអក្សរនៃភាសាអង់គ្លេសក្នុងចំណោមរដ្ឋជាភាគីទាំងឡាយនៅក្នុងតំបន់នោះ ដែលមិនបានចូលរួមជាសមាជិកក្រុមប្រឹក្សាប្រតិបត្តិសំរាប់រយៈពេលដ៏យូរបំផុត ចាប់តាំងពីក្លាយខ្លួនជារដ្ឋភាគី ឬចាប់តាំងពីរយៈពេលកាន់តំណែងចុងក្រោយរបស់ពួកគេ ។ រដ្ឋជាភាគីដែលត្រូវបានតែងតាំង ដោយឈរលើមូលដ្ឋាននេះ អាចសំរេចចិត្តមិនទទួលយកនូវអាសនៈរបស់ខ្លួនបាន ។ក្នុងករណីនេះរដ្ឋភាគីនោះត្រូវបញ្ជូននូវលិខិតលះបង់ចោលនូវអាសនៈនេះទៅអគ្គនាយក ហើយអាសនៈនេះត្រូវបានបំពេញ ដោយរដ្ឋជាភាគីតាមលំដាប់បន្ទាប់ដោយស្របទៅនឹងកថាខណ្ឌរងនេះ ។

គ/ អាសនៈដែលនៅសល់តាមតំបន់ភូមិសាស្ត្រ នឹងត្រូវបានបំពេញដោយរដ្ឋជាភាគីតែងតាំង ក្នុងចំណោមរដ្ឋជាភាគីទាំងអស់នៅក្នុងតំបន់នោះ ដោយការប្តូរវេន ឬ ការបោះឆ្នោត ។

៣០-សមាជិកនីមួយៗនៃក្រុមប្រឹក្សាប្រតិបត្តិ មានអ្នកតំណាងម្នាក់ប្រចាំនៅក្រុមប្រឹក្សាប្រតិបត្តិ ដែលអាចអមដោយតំណាងរង និងទីប្រឹក្សា ។

៣១-សមាជិកនីមួយៗនៃក្រុមប្រឹក្សាប្រតិបត្តិ នឹងកាន់តំណែងចាប់ពីពេលបញ្ចប់នៃសម័យប្រជុំរបស់សន្និសីទដែលសមាជិកនោះ ត្រូវបានបោះឆ្នោតជ្រើសរើសរហូតដល់ពេលចប់សម័យប្រជុំសាមញ្ញលើកទី ២ នៃសន្និសីទ ។ បែបបទនេះមិនអនុវត្តទេ ចំពោះការបោះឆ្នោត លើកទី ១ នៃក្រុមប្រឹក្សាប្រតិបត្តិដោយហេតុថាតាមការបែងចែកអាសនៈ ក្នុងកថាខ័ណ្ឌ ២៨ មានសមាជិកចំនួន ២៦ រូប នៃក្រុមប្រឹក្សាប្រតិបត្តិនេះ នឹងត្រូវបានជ្រើសរើស ដើម្បីកាន់តំណែងរហូតដល់ពេលបញ្ចប់សម័យប្រជុំសាមញ្ញលើកទី ៣ ប្រចាំឆ្នាំ នៃសន្និសីទតែម្តង ។

៣២-ក្រុមប្រឹក្សាប្រតិបត្តិ នឹងរៀបរាប់យ៉ាងល្អិតល្អន់នូវវិធាននៃនីតិវិធីរបស់ខ្លួន ហើយបញ្ជូនវិធាននោះទៅអង្គសន្និសីទ ដើម្បីធ្វើការអនុម័តយល់ព្រម ។

៣៣-ក្រុមប្រឹក្សាប្រតិបត្តិបោះឆ្នោតជ្រើសរើស ប្រធាននៅក្នុងចំណោមសមាជិករបស់ខ្លួន ។

៣៤-ក្រុមប្រឹក្សាប្រតិបត្តិនឹងចូលរួមប្រជុំរាល់សម័យប្រជុំសាមញ្ញ ហើយនៅចន្លោះសម័យប្រជុំនីមួយៗ អាចមានការជួបប្រជុំតាមតំរូវការចាំបាច់ ដើម្បីបំពេញនូវអំណាច និងតួនាទីរបស់ខ្លួន ។

៣៥-សមាជិកនីមួយៗ នៃក្រុមប្រឹក្សាប្រតិបត្តិ មានសំលេងឆ្នោតមួយសំលេង ។

៣៦-ក្រុមប្រឹក្សាប្រតិបត្តិ ធ្វើការសំរេចលើបញ្ហានៃនីតិវិធីតាមមតិភាគច្រើននៃសមាជិកទាំងអស់ ។ក្រុមប្រឹក្សាប្រតិបត្តិធ្វើការសំរេចចិត្តលើបញ្ហាសំខាន់នានា ដោយសំលេងភាគច្រើន ២/៣ នៃសមាជិកទាំងអស់ លើកលែងណាមិនមានការបញ្ជាក់ផ្សេងពីនេះ នៅក្នុងសន្និសញ្ញា ។ នៅពេលបញ្ហាកើតឡើង ថាតើបញ្ហានេះជាបញ្ហាមានសារៈសំខាន់ ឬក៏គ្មាននោះទេ បញ្ហានេះ ត្រូវចាត់ទុកជាបញ្ហាសំខាន់ លើកលែងណាមតិភាគច្រើនមិនបានសំរេចផ្សេងពីនេះ ។

## អំណាច និង តួនាទី

៣៧-ក្រុមប្រឹក្សាប្រតិបត្តិ គឺជាស្ថាប័នប្រតិបត្តិរបស់អង្គការ ។ ក្រុមប្រឹក្សានេះ ទទួលខុសត្រូវចំពោះមុខសន្និសីទ ។ ក្រុមប្រឹក្សាប្រតិបត្តិអនុវត្តនូវអំណាច និងតួនាទីទាំងឡាយជាក់លាក់ ៣៩៥៨២៣១ដោយអនុលោមតាមសន្និសញ្ញានេះ ។

ក្នុងន័យនេះ រាល់សកម្មភាពខ្លួន ត្រូវអនុលោមតាមអនុសាសន៍ សេចក្តីសំរេច និងគោលការណ៍ណែនាំនៃសន្និសីទ និងដើម្បីធានាការបន្តអនុវត្តន៍អោយបានជាក់លាក់នូវឯកសារទាំងនេះ ។

៣៨-ក្រុមប្រឹក្សាប្រតិបត្តិត្រូវ ៖

ក-ជំរុញធ្វើអោយមានប្រសិទ្ធិភាពដល់ការអនុវត្តន៍ និងការប្រព្រឹត្តិតាមសន្និសញ្ញានេះ ។

ខ-ត្រួតពិនិត្យមើលរាល់សកម្មភាពនៃលេខាធិការដ្ឋានបច្ចេកទេស ។

គ-បង្កើតអនុសាសន៍ដ៏ចាំបាច់ចំពោះសន្និសីទ សំរាប់ការពិនិត្យពិច័យនូវសំណើបន្ថែម ដើម្បីបំរុញនូវកម្មវត្ថុ និងគោលបំណងនៃសន្ធិសញ្ញានេះ ។

ឃ-ធ្វើសហប្រតិបត្តិការជាមួយអាជ្ញាធរជាតិនៃរដ្ឋជាភាគីនីមួយៗ ។

ង-ពិនិត្យពិចារណានិងដាក់សំណើដល់សន្និសីទនូវសេចក្ដីព្រាងកម្មវិធីប្រចាំឆ្នាំ និងថវិការបស់អង្គការ សេចក្ដីព្រាងរបាយការណ៍របស់អង្គការស្ដីពីការអនុវត្តន៍សន្ធិសញ្ញានេះរបាយការណ៍ស្ដីអំពីទង្វើសកម្មភាពផ្ទាល់ខ្លួន និងរបាយការណ៍ចាំបាច់ផ្សេងៗទៀតដែលសន្និសីទស្នើសុំ។

ច-រៀបចំចាត់ចែងរាល់សម័យប្រជុំរបស់សន្និសីទ រួមបញ្ចូលទាំងការរៀបចំសេចក្ដីព្រាងកម្មវិធីនៃកិច្ចប្រជុំផងដែរ ។

ឆ-ពិនិត្យសំណើនៃការផ្លាស់ប្ដូរបញ្ហារដ្ឋបាល ឬបច្ចេកទេស ពិធីសារ ឬឧបសម្ព័ន្ធ ដោយអនុលោមតាមមាត្រាទី ៧ ហើយធ្វើអនុសាសន៍ជូនទៅរដ្ឋភាគីទាំងអស់ ចំពោះការអនុម័តយល់ព្រមរបស់ពួកគេ ។

ជ-ចុះកិច្ចព្រមព្រៀង ឬកិច្ចចាត់ចែងសំរុះសំរួល ជាមួយបណ្ដារដ្ឋជាភាគីរដ្ឋផ្សេងៗដទៃទៀត និងអង្គការអន្តរជាតិក្នុងនាមនៃអង្គការក្រោយពីមានការយល់ព្រមពីសន្និសីទ និងគ្រប់គ្រងចំពោះការអនុវត្តន៍កិច្ចព្រមព្រៀងទាំងនេះ ដោយលើកលែងតែកិច្ចព្រមព្រៀង ឬការរៀបចំចាត់ចែងណា ដែលលើកឡើងក្នុង កថាខ័ណ្ឌរង (ឈ )។

ឈ-អនុម័តយល់ព្រម និងត្រួតពិនិត្យមើលនូវកិច្ចប្រតិបត្តិការរបស់កិច្ចព្រមព្រៀង ឬកិច្ចចាត់ចែងនានា ដែលមានការទាក់ទងដល់ការអនុវត្តន៍លើការផ្ទៀងផ្ទាត់រាល់សកម្មភាពនានាជាមួយរដ្ឋជាភាគី និងរដ្ឋដទៃផ្សេងៗទៀត ។

ញ-អនុម័តយល់ព្រមដល់ឯកសារប្រតិបត្តិការថ្មី និងកែប្រែឯកសារប្រតិបត្តិការដែលមានស្នើឡើង ដោយលេខាធិការដ្ឋានបច្ចេកទេស ។

៣៩-ក្រុមប្រឹក្សាប្រតិបត្តិ អាចស្នើសុំបើកសម័យប្រជុំពិសេសរបស់សន្និសីទ ។

៤០-ក្រុមប្រឹក្សាប្រតិបត្តិត្រូវ :

ក-ជួយសំរួលកិច្ចសហប្រតិបត្តិការ ក្នុងបណ្ដាចំណោមរដ្ឋជាភាគីទាំងឡាយ និងរវាងរដ្ឋជាភាគីទាំងអស់ និងលេខាធិការដ្ឋានបច្ចេកទេស ដែលទាក់ទងដល់ការអនុវត្តន៍សន្ធិសញ្ញានេះ ឆ្លងតាមរយៈការផ្លាស់ប្ដូរព័ត៌មានគ្នាទៅវិញទៅមក ។

ខ-ជួយសំរួលដល់ការពិគ្រោះយោបល់ និងការស្រាយបំភ្លឺដល់បណ្ដារដ្ឋជាភាគីទាំងអស់ ដោយយោងតាមមាត្រាទី ៤ និង

គ-ទទួលពិនិត្យលើសំណើ និងរបាយការណ៍ត្រួតពិនិត្យនៅនឹងកន្លែង និងចាត់វិធានការលើសំណើ និងរបាយការណ៍ទាំងនោះដោយអនុលោមតាមមាត្រាទី ៤ ។

៤១-ក្រុមប្រឹក្សាប្រតិបត្តិ ត្រូវពិចារណារាល់បញ្ហាដែលលេចឡើងដោយរដ្ឋជាភាគីស្តីពីការមិនប្រព្រឹត្តិតាមសន្ធិសញ្ញានេះ និងការរំលោភលើសិទ្ធិទាំងឡាយ ដែលបង្កើតឡើងដោយសន្ធិសញ្ញានេះ ។ ក្នុងន័យនេះ ក្រុមប្រឹក្សាប្រតិបត្តិត្រូវពិគ្រោះយោបល់ជាមួយរដ្ឋភាគី ដែលពាក់ព័ន្ធទាំងឡាយ និងស្នើឡើងនូវវិធានការសមស្របទៅរដ្ឋភាគី ដើម្បីចាត់វិធានការក្នុងការកែតំរូវស្ថានភាពទៅតាមពេលវេលាកំណត់ដ៏ជាក់លាក់មួយ ។ ទំហំក្នុងការពិចារណាសកម្មភាពចាំបាច់បន្ថែមទៀត ក្រុមប្រឹក្សាប្រតិបត្តិត្រូវចាត់វិធានការមួយ ឬក៏ច្រើនដូចតទៅ :

ក-ផ្តល់ដំណឹងដល់គ្រប់រដ្ឋជាភាគីទាំងអស់ នូវរាល់រឿងរ៉ាវឬបញ្ហាដែលកើតមានឡើង។

ខ-លើកឡើងនូវបញ្ហា ឬរឿងរ៉ាវផ្សេងៗ ដើម្បីដាក់អោយមានការចាប់អារម្មណ៍ពីអង្គសន្និសីទ ។

គ-ធ្វើអនុសាសន៍ដល់សន្និសីទ ឬចាត់សកម្មភាពដ៏សមស្រប ចំពោះវិធានការកែតំរូវដល់ស្ថានភាព និងធ្វើអោយប្រាកដប្រជាដល់ការប្រព្រឹត្តិតាមបែបបទ ដោយអនុលោមទៅតាមមាត្រាទី ៥ ។

## លេខាធិការដ្ឋានបច្ចេកទេស

៤២-លេខាធិការដ្ឋានបច្ចេកទេស ត្រូវជួយរដ្ឋភាគីទាំងអស់ក្នុងការអនុវត្តន៍សន្ធិសញ្ញានេះ ។ លេខាធិការដ្ឋានបច្ចេកទេស ត្រូវជួយសន្និសីទ និងក្រុមប្រឹក្សាប្រតិបត្តិ ក្នុងការបំពេញតួនាទីរបស់ខ្លួន ។ អនុលោមតាមសន្ធិសញ្ញាកិច្ចព្រមព្រៀងនេះ លេខាធិការដ្ឋានបច្ចេកទេស ត្រូវមានតួនាទីក្នុងការត្រួតពិនិត្យ និងតួនាទីផ្សេងទៀត ដែលប្រគល់ឱ្យលេខាធិការដ្ឋានតាមសន្ធិសញ្ញានេះ ព្រមទាំងតួនាទី ដែលប្រគល់អោយដោយសន្និសីទ ឬក្រុមប្រឹក្សាប្រតិបត្តិស្របតាមសន្ធិសញ្ញានេះ ។ លេខាធិការដ្ឋានបច្ចេកទេស ត្រូវបញ្ចូលមជ្ឈមណ្ឌលទិន្នន័យអន្តរជាតិ ក្នុងក្របខ័ណ្ឌរបស់ខ្លួនទុកដូចជា ផ្នែករួមមួយ ។

៤៣-ដោយអនុលោមតាមមាត្រា ៤ និងពិធីសារ នៃសន្ធិសញ្ញានេះ តួនាទីរបស់លេខាធិការដ្ឋានបច្ចេកទេស ក្នុងការត្រួតពិនិត្យស្របតាមសន្ធិសញ្ញានេះ ត្រូវរាប់បញ្ចូលដូចតទៅ :

ក-ការទទួលខុសត្រូវ ក្នុងការដឹកនាំលើការប្រើប្រាស់ប្រព័ន្ធត្រួតពិនិត្យអន្តរជាតិ និងការសំរបសំរួលដល់ប្រពន្ធ័នេះ ។

ខ-ការប្រើប្រាស់មជ្ឈមណ្ឌលទិន្នន័យអន្តរជាតិ ។

គ-ការសំរបសំរួលអចិន្ត្រៃយ៍ ក្នុងការទទួលការកែច្នៃ ការវិភាគ អំពីទិន្នន័យ នៃប្រព័ន្ធត្រួតពិនិត្យអន្តរជាតិ និងការធ្វើរបាយការណ៍តាមទិន្នន័យ ។

ឃ-ការផ្តល់ជំនួយខាងផ្នែកបច្ចេកទេស និងការផ្គត់ផ្គង់ដល់ការតំឡើង និងការប្រើប្រាស់ស្ថានីយត្រួតពិនិត្យ ។

ង-ការជួយដល់ក្រុមប្រឹក្សាប្រតិបត្តិ ដើម្បីជួយសំរួលលើការពិគ្រោះយោបល់ និងការស្រាយបំភ្លឺក្នុងចំណោមរដ្ឋភាគីទាំងអស់ ។

ច-ការទទួលសំណើសំរាប់ធ្វើអធិការកិច្ចនៅនឹងកន្លែង ( on-site inspection ) និងការជួយសំរួលដល់ក្រុមប្រឹក្សាប្រតិបត្តិ ក្នុងការពិចារណា លើសំណើរៀបចំផ្តល់ជំនួយបច្ចេកទេសក្នុងរយៈពេលធ្វើអធិការកិច្ច និងធ្វើរបាយការណ៍ទៅក្រុមប្រឹក្សាប្រតិបត្តិ ។

ឆ-ធ្វើការចរចា ធ្វើកិច្ចព្រមព្រៀង និងកិច្ចសំរបសំរួលជាមួយរដ្ឋភាគីទាំងអស់ ឬជាមួយរដ្ឋផ្សេងទៀត និងអង្គការអន្តរជាតិនានា រួមទាំងការចុះហត្ថលេខា លើរាល់កិច្ចព្រមព្រៀង និងកិច្ចសំរបសំរួលនានា ដែលទាក់ទងនឹងសកម្មភាពត្រួតពិនិត្យ ជាមួយរដ្ឋភាគីទាំងអស់ ឬរដ្ឋផ្សេងៗទៀត បន្ទាប់ពីមានការអនុម័តយល់ព្រមពីក្រុមប្រឹក្សាប្រតិបត្តិរួចហើយ និង

ជ-ការជួយដល់រដ្ឋភាគីទាំងអស់ តាមរយៈអាជ្ញាធរជាតិរបស់ខ្លួន លើបញ្ហាផ្សេងទៀតដែលទាក់ទងដល់ការត្រួតពិនិត្យស្របតាមសន្ធិសញ្ញានេះ ។

៤៤-លេខាធិការដ្ឋានបច្ចេកទេស ត្រូវបង្កើត និងថែរក្សាស្របតាមការអនុម័ត របស់ក្រុមប្រឹក្សាប្រតិបត្តិនូវក្បួនប្រតិបត្តិការ ( operational manuals )ដើម្បីដឹកនាំប្រតិបត្តិការលើការងារផ្សេងៗនៃរបបត្រួតពិនិត្យ ( virification regime ) ដោយអនុលោមតាមមាត្រា ៤ និងពិធីសារ ។ ក្បួនទាំងនោះ មិនមែនជាផ្នែករបស់សន្ធិសញ្ញានេះនិងពិធីសារទេ និងអាចត្រូវបានផ្លាស់ប្តូរដោយលេខាធិការដ្ឋានបច្ចេកទេសស្របតាមការអនុម័តរបស់ក្រុមប្រឹក្សាប្រតិបត្តិ ។ លេខាធិការដ្ឋានបច្ចេកទេស ត្រូវជូនព័តមានជាបន្ទាន់ដល់រដ្ឋភាគីទាំងអស់ នូវរាល់ការផ្លាស់ប្តូរ នានា ដែលទាក់ទងនឹងក្បួនប្រតិបត្តិការនេះ ។

៤៥-ភារកិច្ចទាំងឡាយ របស់លេខាធិការដ្ឋានបច្ចេកទេស ដែលទាក់ទងនឹងបញ្ហារដ្ឋបាលត្រូវមានដូចតទៅ :

ក-ការរៀបចំ និងការដាក់ឱ្យក្រុមប្រឹក្សាប្រតិបត្តិត្រួតពិនិត្យនូវសេចក្តីព្រាងកម្មវិធី និងថវិការបស់អង្គការ ។

ខ-ការរៀបចំ និងការដាក់ឱ្យក្រុមប្រឹក្សាប្រតិបត្តិពិនិត្យ នូវសេចក្ដីព្រាងនៃរបាយការណ៍របស់អង្គការ អំពីការអនុវត្តន៍នៃសន្ធិសញ្ញានេះ និងរបាយការណ៍ផ្សេងៗទៀត តាមតែសន្និសីទ និងក្រុមប្រឹក្សាប្រតិបត្តិស្នើសុំ ។

គ-ការផ្ដល់នូវការផ្គត់ផ្គង់ផ្នែកបច្ចេកទេស និងរដ្ឋបាលចំពោះសន្និសីទក្រុមប្រឹក្សាប្រតិបត្តិ និងស្ថាប័នក្រោមនិរាទដីទៃទៀត ។

ឃ-ការផ្ញើ និងការទទួលពត៌មានផ្សេងៗ ដែលទាក់ទងនឹងការអនុវត្តន៍សន្ធិសញ្ញានេះ ក្នុងនាមអង្គការ និង

ង-ការបំពេញនូវការទទួលខុសត្រូវផ្នែករដ្ឋបាលដែលទាក់ទងដល់កិច្ចព្រមព្រៀងណាមួយ រវាងអង្គការ និងអង្គការអន្តរជាតិផ្សេងទៀត ។

៤៦-សំណើនិងកំណត់ហេតុទាំងឡាយ ដែលរដ្ឋភាគីដាក់ជូនអង្គការត្រូវធ្វើតាមរយៈអាជ្ញាធរជាតិ ទៅអគ្គនាយក ។ សំណើនិងកំណត់ហេតុទាំងនេះ ត្រូវបានសរសេរជាភាសាផ្លូវការមួយ ក្នុងចំណោមភាសាផ្លូវការទាំងអស់ នៃសន្ធិសញ្ញានេះ ។ ក្នុងការឆ្លើយតបរបស់អគ្គនាយកត្រូវប្រើភាសា ដូចក្នុងសំណើ និងកំណត់ហេតុ ដែលបានផ្ញើជូន ។

៤៧-ទាក់ទងនឹងការទទួលខុសត្រូវ របស់លេខាធិការដ្ឋានបច្ចេកទេស ដើម្បីរៀបចំ និងដាក់ឱ្យក្រុមប្រឹក្សាប្រតិបត្តិត្រួតពិនិត្យសេចក្ដីព្រាងកម្មវិធី និងថវិការបស់អង្គការលេខាដ្ឋានបច្ចេកទេសត្រូវកំណត់ និងអះអាងគណនេយ្យ នៃតំលៃទាំងអស់ឱ្យបានច្បាស់លើឧបករណ៍នីមួយៗ ដែលជាផ្នែកនៃប្រព័ន្ធត្រួតពិនិត្យអន្តរជាតិ ។ ការត្រៀមបំរុងនៅក្នុងគំរោងកម្មវិធី និងថវិកាត្រូវតែទទួលបានការអនុញ្ញាតិស្របតាមសកម្មភាពដីទៃផ្សេងៗទៀតរបស់អង្គការ ។

៤៨-លេខាធិការដ្ឋានបច្ចេកទេស ត្រូវជូនដំណឹងទៅក្រុមប្រឹក្សាប្រតិបត្តិជាបន្ទាន់ជូនលេខាធិការដ្ឋាន នូវរាល់បញ្ហាដែលកើតមានឡើងទាក់ទងនឹងការអនុវត្តន៍តួនាទីរបស់ខ្លួន ហើយដែលជាបញ្ហា នៃការបំពេញការងាររបស់ខ្លួន និងមិនអាចដោះស្រាយបានតាមរយៈ នៃការពិគ្រោះយោបល់ ជាមួយរដ្ឋភាគីពាក់ព័ន្ធទាំងឡាយ ។

៤៩-លេខាធិការដ្ឋានបច្ចេកទេស ត្រូវមានអគ្គនាយក ១ នាក់ ដែលជាអ្នកដឹកនាំ និងជាប្រធានផ្នែករដ្ឋបាលនៃមន្ត្រីផ្នែកវិទ្យាសាស្ត្របច្ចេកទេស និងបុគ្គលិកផ្នែកផ្សេងៗទៀត តាមតែអាចត្រូវបានស្នើសុំ ។ អគ្គនាយកត្រូវបានតែងតាំងក្នុងសន្និសីទ ដោយមានការណែនាំពីក្រុមប្រឹក្សាប្រតិបត្តិសំរាប់អាណត្តិ ៤ ឆ្នាំ ហើយអាចបន្តមួយអាណត្តិទៀតបាន ប៉ុន្តែមិនអាចបន្ត

ថែមទៀតទេ ។ អគ្គនាយកទី ១ ត្រូវតែងតាំង ដោយសន្និសីទក្នុងកិច្ចប្រជុំដំបូងក្រោមការណែនាំរបស់គណៈកម្មការរៀបចំ ។

៤០-អគ្គនាយក ត្រូវទទួលខុសត្រូវចំពោះសន្និសីទ និងក្រុមប្រឹក្សាប្រតិបត្តិសំរាប់ការជ្រើសរើសបុគ្គលិកការដឹកនាំ និងតួនាទីរបស់លេខាធិការដ្ឋានបច្ចេកទេស ។ ការត្រួតពិនិត្យដ៏ធំធេងក្នុងការជួលបុគ្គលិក និងការកំណត់លក្ខខ័ណ្ឌនៃសេវាកម្ម គឺជាការចាំបាច់ក្នុងការធានាឱ្យមាននូវកំរិតខ្ពស់បំផុតនៃជំនាញឯកទេស បទពិសោធន៍ សមត្ថភាព ការទទួលខុសត្រូវ និងភាពសុច្ចរិត ។ មានតែពលរដ្ឋនៃរដ្ឋភាគីទេ ដែលអាចជាអគ្គនាយក ជាអធិការ ឬសមាជិកនៃក្រុមបុគ្គលិកឯកទេស និងស្មៀន ។ អគ្គនាយកត្រូវយកចិត្តទុកដាក់ជាសំខាន់ក្នុងការជ្រើសរើសក្រុមបុគ្គលិកនៅនឹងកន្លែង ដែលមានជំនាញភូមិសាស្ត្រតាមតែអាចធ្វើទៅបាន ។ ការជ្រើសរើសនៅនឹងកន្លែងត្រូវបានធ្វើតាមគោលការណ៍ ត្រូវមានក្រុមបុគ្គលិកយ៉ាងតិចបំផុតស្របតាមតំរូវការចាំបាច់ក្នុងការអនុវត្តន៍ ការទទួលខុសត្រូវរបស់លេខាធិការដ្ឋានបច្ចេកទេស ។

៤១-បន្ទាប់ពីពិគ្រោះយោបល់ជាមួយ លេខាធិការដ្ឋានបច្ចេកទេស អគ្គនាយក អាចបង្កើតក្រុមការងារបណ្តោះអាសន្ន នៃអ្នកជំនាញវិទ្យាសាស្ត្រ ដើម្បីផ្តល់ការណែនាំលើបញ្ហាសំខាន់ៗទាំងពួង ។

៤២-ក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួន អគ្គនាយក អធិការ ជំនួយការអធិការកិច្ច និងសមាជិកនៃក្រុមបុគ្គលិក មិនត្រូវស្វែងរក ឬទទួលបទបញ្ជាពីរដ្ឋាភិបាលនានា ឬក៏ប្រភពផ្សេងៗទៀតក្រៅពីអង្គការឡើយ ។ ពួកគេត្រូវតែចៀសវាងនូវសកម្មភាពមួយចំនួន ដែលនាំឱ្យជះឥទ្ធិពលអាក្រក់ដល់តំណែងរបស់ខ្លួន ជាបុគ្គលិកអន្តរជាតិទទួលខុសត្រូវចំពោះតែអង្គការនេះប៉ុណ្ណោះ ។ អគ្គនាយក ត្រូវភ៌ប់រងការទទួលខុសត្រូវ លើរាល់សកម្មភាព របស់ក្រុមអធិការកិច្ច ។

៤៣-រដ្ឋភាគីនីមួយៗ ត្រូវគោរពទាំងស្រុងចំពោះការទទួលខុសត្រូវ ដែលមានលក្ខណៈអន្តរជាតិរបស់អគ្គនាយក អធិការ ជំនួយការអធិការកិច្ច និងសមាជិកនៃក្រុមបុគ្គលិក និងមិនត្រូវបញ្ចុះបញ្ចូលពួកគេអោយអនុវត្តអ្វីខុសពីការទទួលខុសត្រូវរបស់អ្នកទាំងនោះឡើយ ។

## ខ- បុព្វសិទ្ធិ និង អភ័យឯកសិទ្ធិ

៤៤-ទោះបីនៅលើទឹកដី និងទីកន្លែងដ៏ទៃផ្សេងទៀត ឬស្ថិតនៅក្រោមយុត្តាធិការ ឬការត្រួតពិនិត្យរបស់រដ្ឋភាគីណាមួយក៏ដោយអង្គការត្រូវទទួលនូវនីតិសម្បទាន បុព្វសិទ្ធិ និអភ័យឯកសិទ្ធិទាំងឡាយ ដែលចាំបាច់សំរាប់បំពេញតួនាទីរបស់ខ្លួន ។

៥៥-ប្រតិភូរបស់រដ្ឋភាគីរួមជាមួយ អ្នកជំនួស និងទីប្រឹក្សារបស់គេ អ្នកតំណាងនៃសមាជិកទាំងអស់ ដែលត្រូវបានជ្រើសរើស ដោយក្រុមប្រឹក្សាប្រតិបត្តិ ជាមួយអ្នកជំនួស និងទីប្រឹក្សា អគ្គនាយក អធិការ ជំនួយការអធិការកិច្ច និងសមាជិកនៃក្រុមបុគ្គលិករបស់អង្គការ ត្រូវទទួលបានបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិទាំងឡាយ ដែលចាំបាច់ក្នុងការអនុវត្តនីជាឯករាជ្យនូវតួនាទីរបស់ខ្លួនទាក់ទងនឹងអង្គការ ។

៥៦-នីតិសម្បទាន បុព្វសិទ្ធិ និងអភ័យឯកសិទ្ធិទាំងឡាយ ដែលចែងក្នុងមាត្រានេះ ត្រូវបានកំណត់ក្នុងកិច្ចព្រមព្រៀងទាំងឡាយរវាងអង្គការ និងរដ្ឋភាគីក៏ដូចជាកិច្ចព្រមព្រៀង រវាងអង្គការ និងរដ្ឋដែលអង្គការនោះស្ថិតនៅ ហើយកិច្ចព្រមព្រៀងទាំងនោះត្រូវបានពិនិត្យ និងអនុម័តអនុលោមតាមកថាខ័ណ្ឌ ២៦ ( ជ ) និង (ឈ ) ។

៥៧-ថ្វីបើមានកថាខ័ណ្ឌ ៥៤ និង ៥៥ ក៏ដោយបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិ ដែលមានចំពោះអគ្គនាយក អធិការ ជំនួយការអធិការកិច្ច និងសមាជិក នៃក្រុមបុគ្គលិក របស់លេខាធិការដ្ឋានបច្ចេកទេស ក្នុងទំនាក់ទំនងនឹងសកម្មភាពត្រួតពិនិត្យ ត្រូវបានកំណត់នៅក្នុងពិធីសារ ។

## មាត្រា ៣
## វិធានការ អនុវត្តន៍ថ្នាក់ជាតិ

១-ដោយអនុលោមតាមនីតិវិធីធម្មនុញ្ញរបស់ខ្លួន រដ្ឋភាគីនីមួយៗត្រូវចាត់វិធានការដ៏ចាំបាច់ដើម្បីអនុវត្តកាតព្វកិច្ចរបស់ខ្លួនស្របតាមសន្ធិសញ្ញានេះ ។ ជាពិសេសរដ្ឋនីមួយៗ ត្រូវចាត់វិធានការដូចខាងក្រោម :

ក-ហាមឃាត់នីតិបុគ្គល និងរូបវន្តបុគ្គល ទោះជាស្ថិតលើទឹកដីរបស់ខ្លួន ឬទឹកន្លែងដីទៃទៀត ដែលនៅក្រោមយុត្តាធិការរបស់ខ្លួន ដែលបានទទួលស្គាល់ដោយច្បាប់អន្តរជាតិ ពីការទទួលរ៉ាប់រងលើសកម្មភាពណាមួយ ដែលហាមឃាត់ដល់រដ្ឋភាគីស្របតាមសន្ធិសញ្ញានេះ ។

ខ-ហាមឃាត់នីតិបុគ្គល និងរូបវន្តបុគ្គលពីការធ្វើសកម្មភាពទាំងឡាយណា ដែលស្ថិតក្រោមការត្រួតពិនិត្យរបស់ខ្លួននិង

គ-អនុលោមតាមច្បាប់អន្តរជាតិ ហាមឃាត់រូបវន្តបុគ្គល ដែលមានសញ្ជាតិរបស់ខ្លួនពីការធ្វើសកម្មភាពទាំងអស់ ទោះស្ថិតនៅទីណាក៏ដោយ ។

២-រដ្ឋភាគីនីមួយៗ ត្រូវសហការជាមួយរដ្ឋភាគីដទៃទៀត និងស្វែងរកជំនួយខាងផ្នែកច្បាប់ដើម្បីជួយសំរួលដល់ការអនុវត្តនីកាតព្វកិច្ចស្របតាមកថាខ័ណ្ឌ ១ ។

៣-រដ្ឋភាគីនីមួយៗ ត្រូវជូនដំណឹងទៅអង្គការនូវវិធានការទាំងឡាយ ដែលបានអនុវត្តស្របតាមមាត្រានេះ ។

៤-ដើម្បីបំពេញកាតព្វកិច្ចរបស់ខ្លួន ស្របតាមសន្ធិសញ្ញានេះ រដ្ឋភាគីនីមួយៗ ត្រូវតែងតាំង ឬបង្កើតអាជ្ញាធរជាតិ និងត្រូវជូនដំណឹងពីអាជ្ញាធរនេះ ទៅអង្គការនៅពេលសន្ធិសញ្ញានេះចូលជាធរមាន ។ អាជ្ញាធរជាតិត្រូវជាចំណុចទាក់ទងរួមរបស់ជាតិ ជាមួយអង្គការ និងរដ្ឋភាគីដទៃផ្សេងទៀត ។

## មាត្រា ៤

## ការត្រួតពិនិត្យ

### ក-បទបញ្ញត្តិទូទៅ

១-ដើម្បីត្រួតពិនិត្យស្របតាមសន្ធិសញ្ញានេះ របបនៃការត្រួតពិនិត្យ ត្រូវបានបង្កើតឡើងដោយរួមផ្សំ នូវកម្មវត្ថុសំខាន់ៗ ដូចខាងក្រោម :

ក-ប្រព័ន្ធត្រួតពិនិត្យអន្តរជាតិ ។

ខ-ការពិគ្រោះយោបល់ និងការស្រាយបំភ្លឺ ។

គ-អធិការកិច្ចនៅនឹងកន្លែង និង

ឃ-វិធានការបង្កើតការទុកចិត្តគ្នា ។

នៅពេលសន្ធិសញ្ញានេះចូលជាធរមាន របបត្រួតពិនិត្យត្រូវមានសមត្ថភាព ដើម្បីឆ្លើយតបតាមតំរូវការ នៃការត្រួតពិនិត្យតាមសន្ធិសញ្ញានេះ ។

២-សកម្មភាពនៃការត្រួតពិនិត្យ ត្រូវឈរលើមូលដ្ឋានពត៌មានជាក់ស្តែង តាមកំរិតក្របខ័ណ្ឌបញ្ហានៃសន្ធិសញ្ញានេះ និងប្រព្រឹត្តិទៅឈរលើមូលដ្ឋានគោរពពេញលេញ នូវអធិបតេយ្យភាពនៃរដ្ឋភាគីទាំងឡាយ និងប៉ះពាល់អោយបានតិចបំផុត ដើម្បីសំរេចគោលដៅរបស់រដ្ឋភាគីទាំងនោះ ដោយប្រសិទ្ធភាព និងទាន់ពេលវេលា ។ រដ្ឋភាគីនីមួយៗ ត្រូវជៀសវាងនូវរាល់ការបំពានច្បាប់នៃការត្រួតពិនិត្យ ។

៣-ដោយអនុលោមតាមសន្ធិសញ្ញានេះ រដ្ឋភាគីនីមួយៗ ត្រូវសហការជាមួយអង្គការ និងរដ្ឋភាគីដទៃទៀត តាមរយៈអាជ្ញាធរជាតិ ដែលបង្កើតឡើងស្របតាម មាត្រា ៣ កថាខ័ណ្ឌ ៤ ដើម្បីជួយសំរួលដល់ការត្រួតពិនិត្យស្របតាមសន្ធិសញ្ញានេះ ដូចជា :

ក-ការបង្កើតមធ្យោបាយចាំបាច់ ដើម្បីរួមចំណែកក្នុងវិធានការនៃការត្រួតពិនិត្យ និងការបង្កើតប្រព័ន្ធព័ត៌មានចាំបាច់មួយ ។

ខ-ការផ្តល់ផ្តង់ទិន្នន័យ ដែលទទួលបានពីស្ថានីយជាតិ ដែលជាផ្នែកមួយរបស់ប្រព័ន្ធត្រួតពិនិត្យអន្តរជាតិ ។

គ-ការចូលរួមដោយផ្សែក នៅក្នុងដំណើរការនៃការពិគ្រោះយោបល់ និងស្រាយបំភ្លឺ ។

ឃ-ការអនុញ្ញាតនូវការអនុវត្តន៍ត្រួតពិនិត្យនៅនឹងកន្លែង និង

ង-ការចូលរួមដោយផ្សែក ក្នុងវិធានការបង្កើតការទុកចិត្តគ្នា ។

៤-រដ្ឋភាគីទាំងអស់ដោយមិននិយាយដល់លទ្ធភាពខាងផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ ត្រូវទទួលបានសិទ្ធិស្មើៗគ្នា លើការត្រួតពិនិត្យ និងត្រូវអនុវត្តកាតព្វកិច្ចដោយស្មើភាព ដើម្បីទទួលយកការត្រួតពិនិត្យនេះ ។

៥-ក្នុងគោលបំណងនៃសន្ធិសញ្ញានេះ គ្មានរដ្ឋភាគីណាមួយត្រូវបានហាមឃាត់ លើការប្រើប្រាស់ព័ត៌មាន ដែលទទួលបានពីការត្រួតពិនិត្យដោយប្រព័ន្ធបច្ចេកទេសជាតិ ដើម្បីឱ្យស្របតាមគោលការណ៍នៃច្បាប់អន្តរជាតិ ដែលទទួលស្គាល់ជាទូទៅព្រមទាំងគោរពតាមអធិបតេយ្យភាព នៃរដ្ឋទាំងឡាយ ។

៦-ដោយមិនប៉ះពាល់ដល់សិទ្ធិ នៃរដ្ឋភាគីក្នុងការការពារកន្លែងសំខាន់ៗ សកម្មភាពផ្សេងៗ ឬការស្ថិតនៅ ដែលមិនទាក់ទងនឹងសន្ធិសញ្ញានេះ រដ្ឋភាគីទាំងអស់ មិនត្រូវជ្រៀតជ្រែកដល់ធាតុសំខាន់ៗនៃរបបត្រួតពិនិត្យរបស់សន្ធិសញ្ញា ឬប្រតិបត្តិការនៃការត្រួតពិនិត្យ ដោយប្រព័ន្ធបច្ចេកទេសជាតិ ដោយអនុលោមតាម កថាខ័ណ្ឌ ៥ ។

៧-រដ្ឋភាគីនីមួយៗ មានសិទ្ធិចាត់វិធានការ ដើម្បីការការពារកន្លែងសំខាន់ៗ និងការទប់ស្កាត់ការផ្សាយចេញ នូវទិន្នន័យ និងព័ត៌មានសំងាត់ ដែលមិនទាក់ទងនឹងសន្ធិសញ្ញានេះ ។

៨-លើសពីនេះទៅទៀត វិធានការសំខាន់ៗ ត្រូវបានចាត់ ដើម្បីការពារដល់ព័ត៌មានសំងាត់ទាំងឡាយ ដែលទាក់ទងនឹងសកម្មភាពស៊ីវិល និងយោធា និងកម្មវត្ថុផ្សេងទៀត ដែលទទួលបានក្នុងពេលសកម្មភាពត្រួតពិនិត្យនេះ ។

៩-អនុលោមតាម កថាខ័ណ្ឌ ៨ សន្ធិសញ្ញានេះ ព័ត៌មានដែលអង្គការទទួលបានតាមរយៈរបបត្រួតពិនិត្យ ដែលបង្កើតឡើង ត្រូវបានអនុញ្ញាតដល់រដ្ឋភាគីទាំងអស់ស្របតាមបទបញ្ញត្តិនានានៃសន្ធិសញ្ញានេះ និងពិធីសារ ។

១០-បទបញ្ញត្តិទាំងឡាយ នៃសន្ធិសញ្ញានេះ មិនត្រូវបានបកស្រាយជាការកំរិតលើការផ្លាស់ប្តូរទិន្នន័យជាអន្តរជាតិសំរាប់គោលបំណងវិទ្យាសាស្ត្រនោះទេ ។

១១-រដ្ឋភាគីនីមួយៗ ត្រូវសហការជាមួយអង្គការ និងរដ្ឋដទៃទៀត ក្នុងការធ្វើអោយកាន់តែប្រសើរឡើងនូវរបបត្រួតពិនិត្យ និងក្នុងការសិក្សាមើលលទ្ធភាពប្រកបដោយសក្តានុពលនៃការត្រួតពិនិត្យបន្ថែមទៅ លើបច្ចេកវិទ្យានៃការត្រួតពិនិត្យ ដូចជាការត្រួតពិនិត្យតាមកំលាំងដែនម៉ាញេទិច ឬការត្រួតពិនិត្យតាមប្រព័ន្ធផ្កាយរណប ក្នុងគោលបំណងនៃការអភិវឌ្ឍន៍ ក្នុងស្ថានភាពចាំបាច់លើវិធានការជាក់លាក់មួយ ដើម្បីជួយបង្កើនការត្រួតពិនិត្យក្រោមសន្ធិសញ្ញានេះប្រកបដោយសមត្ថភាព និងមានប្រសិទ្ធភាពខ្ពស់ ។ វិធានការទាំងនោះត្រូវបានបញ្ចូលទៅក្នុងបទបញ្ញត្តិទាំងឡាយនៃសន្ធិសញ្ញានេះ ពិធីសារ ឬផ្នែកបន្ថែមផ្សេងទៀតនៃពិធីសារ ដោយអនុលោមតាមមាត្រា ៧ ឬក្នុងឱកាសសមស្របត្រូវបានបង្ហាញឱ្យឃើញក្នុងការដឹកនាំប្រតិបត្តិការស្របទៅតាម កថាខ័ណ្ឌ ៤៤ នៃមាត្រា ២ ។

១២-រដ្ឋភាគីមានកាតព្វកិច្ចបង្កើនកិច្ចសហប្រតិបត្តិការរវាងគ្នា ដើម្បីជួយសំរួល និងចូលរួមក្នុងការផ្លាស់ប្តូរពេញលេញនូវបច្ចេកវិជ្ជា ដែលបានប្រើប្រាស់ក្នុងការត្រួតពិនិត្យ នៃសន្ធិសញ្ញានេះ ដើម្បីជួយឱ្យរដ្ឋភាគីទាំងអស់ ពង្រឹងការអនុវត្តន៍វិធានការនៃការត្រួតពិនិត្យរបស់ជាតិ និងទាញយកផលប្រយោជន៍ពីការប្រើប្រាស់បច្ចេកវិជ្ជាទាំងនោះ សំរាប់គោលបំណងសន្តិភាព ។

១៣-បទបញ្ញត្តិទាំងឡាយនៃសន្ធិសញ្ញានេះ ត្រូវបានអនុវត្តក្នុងរបៀបយ៉ាងណា ដើម្បីបញ្ចៀសផលការរារាំងដំណើរការអភិវឌ្ឍន៍បច្ចេកវិជ្ជា និងសេដ្ឋកិច្ចរបស់រដ្ឋភាគី សំរាប់ការរីកចំរើនទៅមុខ នៃការប្រើប្រាស់កំលាំងអាតូមិច ក្នុងគោលបំណងសន្តិភាព ។

## ការទទួលខុសត្រូវ លើការត្រួតពិនិត្យរបស់លេខាធិការដ្ឋានបច្ចេកទេស

១៤-ក្នុងការបំពេញការទទួលខុសត្រូវរបស់ខ្លួន លើផ្នែកត្រួតពិនិត្យដែលបានបញ្ជាក់ក្នុងសន្ធិសញ្ញា និងពិធីសារក្នុងកិច្ចសហប្រតិបត្តិការ ជាមួយរដ្ឋជាភាគីលើគោលបំណងនៃសន្ធិសញ្ញានេះ លេខាធិការដ្ឋានបច្ចេកទេសត្រូវ :

ក-អនុលោមតាមបទបញ្ញត្តិនៃសន្ធិសញ្ញានេះ ចាត់វិធានការក្នុងការទទួល និងការផ្សព្វផ្សាយទិន្នន័យ និងរបាយការណ៍ផលិតផល ដែលទាក់ទងនឹងការត្រួតពិនិត្យ និងថែរក្សាហេដ្ឋារចនាសម្ពន្ធ័ បណ្តាញពត៌មានយ៉ាងទូលំទូលាយឱ្យបានសមស្របតាមការងារនេះ ។

ខ-តាមរយៈមជ្ឈមណ្ឌលទិន្នន័យអន្តរជាតិ ដែលជាគោលការណ៍ ជាចំនុចប្រសព្វនៃការថែរក្សា និងការរៀបចំនៃទិន្នន័យ ក្នុងក្របខ័ណ្ឌលេខាធិការដ្ឋានបច្ចេកទេសជាប្រចាំ :

(I)-ទទួល និងផ្តួចផ្តើមសំណើទាក់ទងនឹងទិន្នន័យពីប្រព័ន្ធត្រួតពិនិត្យអន្តរជាតិ ។

(II)-ទទួលទិន្នន័យបានមកពីការពិគ្រោះយោបល់ និងការបញ្ជាក់ច្បាស់លាស់មកពីការត្រួតពិនិត្យនៅនឹងកន្លែង និងមកពីការអនុវត្តនីតិវិធានការនៃការបង្កើតជំនឿទុកចិត្ត និង

(III)-ទទួលទិន្នន័យពាក់ព័ន្ធដទៃទៀតពីរដ្ឋភាគី និងអង្គការអន្តរជាតិនានា ដោយអនុលោមតាមសន្ធិសញ្ញា និងពិធីសារនេះ ។

គ-គ្រប់គ្រងសំរបសំរួល និងធានាកិច្ចប្រតិបត្តិការរបស់ប្រព័ន្ធត្រួតពិនិត្យអន្តរជាតិ និងផ្នែកផ្សេងៗរបស់វា និងដល់មជ្ឈមណ្ឌលទិន្នន័យអន្តរជាតិ ដោយអនុលោមតាមសៀវភៅប្រតិបត្តិការ ។

ឃ-ឈរលើមូលដ្ឋានដដែលនេះ អនុវត្តដំណើរវិភាគ និងរាយការណ៍ អំពីទិន្នន័យនៃប្រព័ន្ធត្រួតពិនិត្យអន្តរជាតិស្របតាមនីតិវិធី ដែលបានព្រមព្រៀង ដើម្បីផ្តល់ផ្តង់ការត្រួតពិនិត្យអន្តរជាតិឱ្យមានប្រសិទ្ធិភាពក្រោមសន្ធិសន្ធិសញ្ញានេះ និងជួយសំរេចនូវកង្វល់ នៃការគោរពប្រតិបត្តិអោយបានឆាប់ ។

ង-អនុញ្ញាតិអោយប្រើប្រាស់ទិន្នន័យទាំងអស់ ទាំងមិនទាន់បានពិនិត្យ និងទាំងបានពិនិត្យ ហើយរួមទាំងលទ្ធផលរបាយការណ៍ដល់រដ្ឋភាគីទាំងអស់ ដែលក្នុងនោះរដ្ឋភាគីនីមួយៗ ទទួលខុសត្រូវលើការប្រើប្រាស់ទិន្នន័យ នៃប្រព័ន្ធត្រួតពិនិត្យអន្តរជាតិស្របទៅតាមកថាខ័ណ្ឌ ៧-៨ និង ១៣ នៃមាត្រា ២ ។

ច-ផ្តល់ឱ្យរដ្ឋភាគីទាំងអស់ នូវលទ្ធភាពប្រើប្រាស់ទិន្នន័យ ដែលរក្សាទុកដោយស្មើភាពជាចំហរ ដោយងាយស្រួល និងគ្រប់ពេលវេលា ។

ឆ-រក្សាទុកទិន្នន័យទាំងអស់ មិនទាន់បានពិនិត្យ ទាំងបានពិនិត្យ ហើយរួមទាំងលទ្ធផលរបាយការណ៍ផងដែរ ។

ជ-សំរបសំរួល និងជួយសំរួលរាល់សំណើរ លើទិន្នន័យបន្ថែមផ្សេងៗ ពីប្រព័ន្ធត្រួតពិនិត្យអន្តរជាតិ ។

ឈ-សំរបសំរួលរាល់សំណើរ លើទិន្នន័យបន្ថែម ពីរដ្ឋភាគីមួយទៅរដ្ឋភាគីដទៃទៀត ។

ញ-ផ្តល់ជំនួយបច្ចេកទេស និងការគាំទ្រ ក្នុងការតំឡើង និងប្រតិបត្តិលើឧបករណ៍ត្រួតពិនិត្យ និងប្រព័ន្ធពត៌មានសមស្របនៅទីណា ដែលរដ្ឋពាក់ព័ន្ធត្រូវការជំនួយ និងការឧបត្ថម្ភ ។

ជ-ផ្តល់លទ្ធភាពប្រើប្រាស់ដល់គ្រប់រដ្ឋភាគី ដែលបានលើកសំណើ នូវឧបករណ៍ ដែលត្រូវបានប្រើប្រាស់ ដោយលេខាធិការដ្ឋានបច្ចេកទេស និងតាមមជ្ឈមណ្ឌលទិន្នន័យអន្តរជាតិ ក្នុងការប្រមូលផ្តុំរក្សាទុក កែច្នៃវិភាគ និងធ្វើឱ្យសំរេចទិន្នន័យ ពីរបបត្រួតពិនិត្យ និង

ឆ-អនុវត្តការត្រួតពិនិត្យ ការវាយតំលៃ និងរបាយការណ៍ អំពីការបំពេញមុខងារទូទៅនៃប្រព័ន្ធត្រួតពិនិត្យអន្តរជាតិ និងមជ្ឈមណ្ឌលអន្តរជាតិ ។

១៥-នីតិវិធី ដែលលេខាធិការដ្ឋានបច្ចេកទេសព្រមព្រៀងប្រើប្រាស់ ក្នុងការបំពេញភារកិច្ចក្នុងផ្នែកត្រួតពិនិត្យ ដែលបានបញ្ជាក់ក្នុងកថាខ័ណ្ឌ ១៤ និងបញ្ជាក់លំអិតក្នុងពិធីសារត្រូវធ្វើឱ្យកាន់តែប្រសើរក្នុងស្ទូនប្រតិបត្តិការ ។

## ខ-ប្រព័ន្ធត្រួតពិនិត្យអន្តរជាតិ

១៦-ប្រព័ន្ធត្រួតពិនិត្យអន្តរជាតិ រាប់បញ្ចូលទាំងគ្រឿងប្រដាប់ សំរាប់ការត្រួតពិនិត្យ ស៊ីសមិច ( seismological ) ការត្រួតពិនិត្យវិទ្យុនុយក្លេអ៊ែរ ( Radionuclide )ជាមួយមន្ទីរពិសោធន៍ត្រឹមត្រូវ ការត្រួតពិនិត្យហ៊ីដ្រូអាកូស្ទិច ( Hydroacoustic ) និងប្រព័ន្ធទាក់ទងពត៌មាន នឹងត្រូវបានជួយគាំទ្រដោយមជ្ឈមណ្ឌលទិន្នន័យអន្តរជាតិរបស់លេខាធិការដ្ឋានបច្ចេកទេស ។

១៧-ប្រព័ន្ធត្រួតពិនិត្យអន្តរជាតិ ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងលេខាធិការដ្ឋានបច្ចេកទេស ។ គ្រឿងប្រដាប់សំរាប់ត្រួតពិនិត្យទាំងអស់ របស់ប្រព័ន្ធត្រួតពិនិត្យអន្តរជាតិ ត្រូវបានស្ថិតនៅជាកម្មសិទ្ធិរបស់រដ្ឋម្ចាស់ផ្ទះ ឬរដ្ឋដែលទទួលខុសត្រូវចំពោះគ្រឿងប្រដាប់ទាំងនោះ ស្របទៅតាមពិធីសារ ។

១៨-រដ្ឋភាគីនីមួយៗ មានសិទ្ធិចូលរួម ក្នុងការផ្លាស់ប្តូរទិន្នន័យជាអន្តរជាតិ និងមានលទ្ធភាពប្រើប្រាស់ទិន្នន័យទាំងអស់ ដែលបានអនុញ្ញាតិអោយប្រើប្រាស់ ពីមជ្ឈមណ្ឌលទិន្នន័យអន្តរជាតិ ។ រដ្ឋភាគីនីមួយៗត្រូវសហការជាមួយមជ្ឈមណ្ឌលទិន្នន័យអន្តរជាតិតាមរយៈអាជ្ញាធរជាតិរបស់គេ ។

## មូលនិធិ នៃប្រព័ន្ធត្រួតពិនិត្យអន្តរជាតិ

១៩-ទាក់ទងឧបករណ៍ ដែលបានបញ្ចូលទៅក្នុងប្រព័ន្ធត្រួតពិនិត្យអន្តរជាតិ និងដែលបានបង្ហាញក្នុងតារាងទី ១-ក ២-ក ទី ៣ និង ទី ៤ នៃឧបសម្ព័ន្ធ ១ ទៅក្នុងពិធីសារ និងការប្រើប្រាស់របស់ឧបករណ៍ទាំងនោះ ដល់កំរិតមួយដែលឧបករណ៍ទាំងនោះ តាមការព្រមព្រៀងរវាងរដ្ឋ និងអង្គការពាក់ព័ន្ធសំរាប់ការផ្គត់ផ្គង់ទិន្នន័យទៅមជ្ឈមណ្ឌលទិន្នន័យអន្តរជាតិស្របទៅតាមតំរូវការបច្ចេកទេស នៃពិធីសារ និងស្តូនប្រតិបត្តិការពាក់ព័ន្ធ ដូចដែលបានបញ្ជាក់ក្នុងកិច្ចព្រមព្រៀង ឬការព្រមព្រៀងស្របទៅតាមផ្នែក ទី ១ កថាខ័ណ្ឌ ៤ នៃពិធីសារអង្គការត្រូវចេញចំណាយលើ :

ក-ការបង្កើតរាល់ឧបករណ៍ថ្មីទាំងឡាយ និងកែលំអរឧបករណ៍ដែលមាន ប្រសិនបើរដ្ឋដែលទទួលខុសត្រូវមិនធ្វើការចំណាយដោយខ្លួនឯង ។

ខ-ការប្រើប្រាស់ និងការថែរក្សាឧបករណ៍នៃប្រព័ន្ធត្រួតពិនិត្យអន្តរជាតិដោយរាប់បញ្ចូលផ្នែកសន្តិសុខលើរូបរាងកាយ ប្រសិនឱកាសចាំបាច់និងការប្រើប្រាស់នីតិវិធីស្របច្បាប់នៃទិន្នន័យដែលបានព្រមព្រៀង ។

គ-ការបញ្ជូនទិន្នន័យនៃប្រព័ន្ធត្រួតពិនិត្យអន្តរជាតិ (ដំបូង ឬកែឆ្នៃ) ទៅមជ្ឈមណ្ឌលទិន្នន័យអន្តរជាតិ តាមប្រព័ន្ធដែលផ្ទាល់បំផុត និងមានប្រសិទ្ធភាពបំផុត ហើយប្រសិនចាំបាច់តាមរយៈប្រព័ន្ធពត៌មានពីស្ថានីយត្រួតពិនិត្យ ពិសោធន៍ឧបករណ៍វិភាគ ឬពីមជ្ឈមណ្ឌលទិន្នន័យជាតិ ហើយទិន្នន័យទាំងនោះ រាប់បញ្ចូលទាំងការសាកល្បងក្នុងកាលៈទេសៈចាំបាច់ពីស្ថានីយត្រួតពិនិត្យទៅឧបករណ៍សាកពិសោធន៍ និងវិភាគ និង

ឃ-ការសាកល្បងវិភាគ ក្នុងនាមអង្គការ ។

២០-ការប្រើប្រាស់ស្ថានីយស្ទង់កំរិតរញ្ជួយផែនដីនៃប្រព័ន្ធជំនួយ ដែលបង្ហាញក្នុងតារាងទី ១ ខ នៃឧបសម្ព័ន្ធ ១ នៃពិធីសារ ដូចបានបញ្ជាក់ក្នុងកិច្ចព្រមព្រៀង និងការព្រមព្រៀងទាំងឡាយស្របទៅតាមផ្នែកទី ១ កថាខ័ណ្ឌ ៤ របស់ពិធីសារ អង្គការត្រូវចេញចំណាយត្រឹមតែ :

ក-ការបញ្ជូនទិន្នន័យទៅមជ្ឈមណ្ឌលទិន្នន័យអន្តរជាតិ ។

ខ-ការបញ្ជាក់ពីភាពត្រឹមត្រូវលើទិន្នន័យពីស្ថានីយ៍ទាំងឡាយ ។

គ-ការកែលំអស្ថានីយ៍ដល់កំរិតបច្ចេកទេសស្តង់ដារដែលចាំបាច់ ប្រសិនបើរដ្ឋដែលទទួលខុសត្រូវមិនចំណាយដោយខ្លួនឯងលើឧបករណ៍ទាំងនោះ ។

ឃ-ការបង្កើតស្ថានីយ៍ថ្មី ក្នុងកាលៈទេសៈចាំបាច់សំរាប់គោលបំណងចំពោះទីណាដែលគ្មានឧបករណ៍សមស្រប ប្រសិនបើការចំណាយទាំងនោះ មិនត្រូវបានចំណាយដោយរដ្ឋទទួលខុសត្រូវសំរាប់ឧបករណ៍ទាំងនោះ ។

ង-រាល់ការចំណាយផ្សេងដ៏ទៃទៀត ដែលទាក់ទងដល់ការផ្គត់ផ្គង់ទិន្នន័យ ដែលបានទាមទារដោយអង្គការដូចបានកំណត់ក្នុងសៀវភៅណែនាំប្រតិបត្តិការ ។

២១-អង្គការត្រូវបង់ថ្លៃផ្គត់ផ្គង់ទៅរដ្ឋភាគីនីមួយៗ នូវការជ្រើសរើសដែលបានទាមទារ ដោយអង្គការពីកំរិតគំរូស្តង់ដារលើផលិតផលសំរេច និងសេវាកម្មដូចបានបញ្ជាក់ក្នុងផ្នែក ១ ចំនុច ធ នៃពិធីសារ ។ តំលៃសំរាប់ការរៀបចំ និងការបញ្ជូនទិន្នន័យបន្ថែមនានា ឬផលិតផលផ្សេងៗ ត្រូវបានចំណាយដោយរដ្ឋភាគីដែលស្នើសុំ ។

២២-កិច្ចព្រមព្រៀងទាំងឡាយ ឬកិច្ចសំរបសំរួលនានា ដែលធ្វើឡើងជាមួយរដ្ឋភាគី ឬរដ្ឋម្ចាស់ផ្ទះ ឬរដ្ឋដែលទទួលខុសត្រូវដល់ឧបករណ៍នៃប្រព័ន្ធត្រួតពិនិត្យអន្តរជាតិ ត្រូវមានចែងបទបញ្ញត្តិដែលទាក់ទង និងការផ្គត់ផ្គង់ការចំណាយទាំងនោះ ។ បទបញ្ញត្តិទាំងនោះ ត្រូវបញ្ចូលលក្ខខ័ណ្ឌផ្សេងៗ ដែលធ្វើឱ្យរដ្ឋភាគីរ៉ាប់រងលើរាល់ការចំណាយ ដូចបានចែងក្នុងកថាខណ្ឌ ១៩ក និង ២០ត និង ឃ ដល់ឧបករណ៍ទាំងឡាយដែលរដ្ឋភាគីនោះទទួលយក ឬទទួលខុសត្រូវ និងទទួលបានការទូទាត់ពីការកាត់បន្ថយសមស្រប លើខ្ទង់ចំណាយជាវិភាគទានដល់អង្គការ ។ ការកាត់បន្ថយទាំងនោះ ធ្វើមិនឱ្យលើសពី ៥០ ភាគរយ នៃខ្ទង់ជំនួយវិភាគទានប្រចាំឆ្នាំរបស់រដ្ឋជាភាគីទេ ក៏ប៉ុន្តែអាចបន្តទៅឆ្នាំក្រោយៗទៀត ។ រដ្ឋភាគីអាចចែកការកាត់បន្ថយទាំងនោះជាមួយរដ្ឋដ៏ទៃផ្សេងទៀត តាមរយៈកិច្ចព្រមព្រៀង ឬកិច្ចសំរបសំរួលរវាងគ្នា និងមានការយល់ព្រមរបស់ក្រុមប្រឹក្សាប្រតិបត្តិ ។ កិច្ចព្រមព្រៀង ឬកិច្ចសំរបសំរួលទាំងឡាយចែងក្នុងកថាខ័ណ្ឌនេះ ត្រូវបានអនុម័តស្របទៅតាមមាត្រាទី ២ កថាខ័ណ្ឌទី ២៦ ជ និង ៣៨ ឈ ។

## ការកែប្រែនៅក្នុងប្រព័ន្ធត្រួតពិនិត្យអន្តរជាតិ

២៣-រាល់វិធានការដូចចែងក្នុងកថាខ័ណ្ឌ ១១ ដែលមានប្រយោជន៍ដល់ប្រព័ន្ធត្រួតពិនិត្យអន្តរជាតិតាមរយៈការដាក់បន្ថែម ឬដកចេញបច្ចេកវិទ្យាត្រួតពិនិត្យដែលបានព្រមព្រៀងរួចហើយ ត្រូវបានបញ្ចូលទៅក្នុងសន្ធិសញ្ញា និងពិធីសារស្របតាមមាត្រា ៧ កថាខ័ណ្ឌ ១ ដល់ ៦ ។

២៤-ការកែប្រែជាបន្តបន្ទាប់នៅក្នុងប្រព័ន្ធត្រួតពិនិត្យអន្តរជាតិ អាស្រ័យតាមការព្រមព្រៀង នៃប្រទេសដែលប៉ះពាល់ផ្ទាល់ទាំងនោះ ត្រូវចាត់ទុកជាបញ្ហា ដែលមានលក្ខណៈជារដ្ឋបាល ឬបច្ចេកទេសស្របទៅតាមកថាខ័ណ្ឌ ៧ និង ៨ នៃមាត្រា ៧ :

ក-ការផ្លាស់ប្តូរនៃចំនួនឧបករណ៍ ដែលមានកំណត់ក្នុងពិធីសារសំរាប់បច្ចេកវិជ្ជាត្រួតពិនិត្យ និង

ខ-ការផ្លាស់ប្តូរគ្រឿងសំភារៈលំអិតដទៃទៀត នៃឧបករណ៍ដូចបានបង្ហាញក្នុងតារាងនានា នៃឧបសម្ព័ន្ធ ១ ក្នុងពិធីសារ ( ដោយរាប់បញ្ចូលដូចជារដ្ឋ ដែលទទួលខុសត្រូវលើឧបករណ៍ កន្លែងស្ថិតនៅ ឈ្មោះឧបករណ៍ ប្រភេទនៃឧបករណ៍ និងការភ្ជាប់ឧបករណ៍ រវាងប្រព័ន្ធស្ទង់កំរិតរញ្ជួយផែនដី ដែលជាគ្រឿងជំនួយបន្ថែម ) ។ ប្រសិនបើក្រុមប្រឹក្សាប្រតិបត្តិផ្តល់សេចក្តីយល់ព្រមទទួលយកការផ្លាស់ប្តូរទាំងនោះ ស្របតាមកថាខ័ណ្ឌ ៨ នៃមាត្រា ៧ តាមច្បាប់ក្រុមប្រឹក្សាប្រតិបត្តិក៏ត្រូវផ្តល់សេចក្តីយល់ព្រមស្របតាមកថាខ័ណ្ឌ ៨ ឃ នៃមាត្រា ៧ ដើម្បីអោយការផ្លាស់ប្តូរទាំងនោះចូលជាធរមាន បញ្ញត្តិ គឺនៅពេលមានការជូនដំណឹងពីអគ្គនាយកតាមការយល់ព្រមរបស់ពួកគេ ។

២៥-ក្នុងការបញ្ជូនទៅក្រុមប្រឹក្សាប្រតិបត្តិ និងរដ្ឋភាគីនូវពត៌មាន និងការវាយតំលៃស្របទៅតាមកថាខ័ណ្ឌ ៨ នៃមាត្រា ៧ អគ្គនាយក ត្រូវបញ្ចូលករណីសំណើផ្សេងៗ ដែលលើកឡើងស្របតាមកថាខ័ណ្ឌ ២៤ :

ក-ការវាយតំលៃផ្នែកបច្ចេកទេសនៃសំណើ ។

ខ-សេចក្តីប្រកាសអំពីផលប៉ះពាល់នៃសំណើ លើផ្នែករដ្ឋបាល និងហិរញ្ញវត្ថុ ។

គ-របាយការណ៍ អំពីការពិគ្រោះយោបល់ជាមួយរដ្ឋទាំងឡាយ ដែលបានប៉ះពាល់ផ្ទាល់ ដោយសារសំណើ ដោយបញ្ចូលទាំងការយល់ព្រមរបស់រដ្ឋទាំងនោះផង ។

## កិច្ចសំរបសំរួលបណ្តោះអាសន្ន

២៦-ក្នុងករណីឧបករណ៍សំរាប់ត្រួតពិនិត្យខូចមួយផ្នែក ឬទាំងស្រុងដូចបានបញ្ជាក់ក្នុងតារាង នៃឧបសម្ព័ន្ធ ១ នៃពិធីសារ ឬដើម្បីទូទាត់តម្លៃនៃការបញ្ឈប់បណ្តោះអាសន្នលើទំហំនៃការត្រួតពិនិត្យ អគ្គនាយកត្រូវមានការពិគ្រោះយោបល់ និងព្រមព្រៀងជាមួយរដ្ឋភាគីទាំងនោះ ដែល

ប៉ះពាល់ដោយផ្ទាល់ត្រូវធ្វើកិច្ចសំរបសំរួលបណ្តោះអាសន្ន ដែលមានរយៈពេលមិនឲ្យលើសពី ១ ឆ្នាំ ហើយអាចបន្ត ១ ឆ្នាំទៀត ប្រសិនបើចាំបាច់តាមកិច្ចព្រមព្រៀងរវាងក្រុមប្រឹក្សាប្រតិបត្តិ និងរដ្ឋទាំងឡាយ ដែលបានទទួលរងនូវការប៉ះពាល់ដោយផ្ទាល់ ។ កិច្ចសំរបសំរួលទាំងនោះ មិនត្រូវធ្វើឲ្យចំនួនឧបករណ៍ប្រតិបត្តិការ នៃប្រព័ន្ធត្រួតពិនិត្យអន្តរជាតិលើសពីចំនួនឧបករណ៍ដូច ដែលបានកំណត់ក្នុងបណ្តាញឡើយ ហើយត្រូវសមស្របតាមតំរូវការបច្ចេកទេស និងប្រតិបត្តិការ ដែលមានកំណត់ក្នុងសៀវភៅប្រតិបត្តិការ នឹងត្រូវបានធ្វើតាមការកំណត់ថវិការបស់អង្គការ ។ ក្រៅពីនេះ អគ្គនាយកត្រូវមានវិធានការជាជំហានៗ ដោយមានការកែលំអស្ថានភាព និងលើកសំណើសំរាប់ការដោះស្រាយជាអចិន្ត្រៃយ៍ ។ អគ្គនាយក ត្រូវជូនដំណឹងទៅរដ្ឋភាគីទាំងអស់នូវរាល់សេចក្តីសំរេចផ្សេងៗ ដែលបានអនុម័តស្របតាមកថាខណ្ឌនេះ ។

## ឧបករណ៍សហការជាតិ

២៧-រដ្ឋភាគីទាំងឡាយ ក៏អាចបង្កើតវិធានការដោយឡែកពីគ្នាជាមួយអង្គការ ដោយឈរលើមូលដ្ឋានកិច្ចសហការ ដើម្បីអនុញ្ញាតឲ្យប្រើប្រាស់ដល់មជ្ឈមណ្ឌលទិន្នន័យនូវទិន្នន័យបន្ថែមដែលបានមកពីស្ថានីយ៍ត្រួតពិនិត្យជាតិ ដែលមិនមែនជាផ្នែកផ្លូវការរបស់ប្រពន្ធ័ត្រួតពិនិត្យអន្តរជាតិ។

២៨-កិច្ចសំរបសំរួលសហប្រតិបត្តិការទាំងនោះ អាចត្រូវបានបង្កើតដូចខាងក្រោម :

ក-តាមសំណើរបស់រដ្ឋភាគី លេខាធិការដ្ឋានបច្ចេកទេសត្រូវចាត់ការជាជំហាន ដែលជាបន្ទុកចំណាយរបស់រដ្ឋនោះ ដើម្បីបញ្ជាក់ថាឧបករណ៍ត្រួតពិនិត្យ ដែលបានប្រគល់ឲ្យនោះ ឆ្លើយតបតាមតំរូវការបច្ចេកទេស និងប្រតិបត្តិដូចដែលបានបង្ហាញក្នុងសៀវភៅប្រតិបត្តិការសមស្របតាមឧបករណ៍នៃប្រពន្ធ័ត្រួតពិនិត្យអន្តរជាតិ និងចាត់វិធានការតាមការពិតជាក់ស្តែងនៃទិន្នន័យរបស់វា ។ អនុលោមតាមកិច្ចព្រមព្រៀងរបស់ក្រុមប្រឹក្សាប្រតិបត្តិ លេខាធិការដ្ឋានបច្ចេកទេសត្រូវដាក់ជាផ្លូវការនូវឧបករណ៍ទាំងនោះ ក្នុងឋានៈជាឧបករណ៍ដែលជាកិច្ចសហការរវាងជាតិ ។ លេខាធិការបច្ចេកទេស ក្នុងកាលៈទេសៈសមស្របត្រូវចាត់ជាជំហានៗ ដែលចាំបាច់ក្នុងការវាយតំលៃជាថ្មី លើឧបករណ៍ទាំងនោះ អោយបានសមស្រប ។

ខ-លេខាធិការដ្ឋានបច្ចេកទេស ត្រូវរក្សាបញ្ជីអំពីឧបករណ៍រវាងជាតិ និងត្រូវផ្សព្វផ្សាយបែងចែកបញ្ជីនោះ ដល់រដ្ឋភាគីទាំងអស់ និង

គ-មជ្ឈមណ្ឌលទិន្នន័យអន្តរជាតិ ត្រូវស្នើរពត៌មានអំពីទិន្នន័យពីឧបករណ៍សហការជាតិ ក្នុងករណីមានការស្នើសុំពីរដ្ឋភាគី សំរាប់គោលបំណងជួយសំរួលដល់ការពិគ្រោះយោបល់ និង

ការបកស្រាយបំភ្លឺ និងការពិនិត្យលើការត្រួតពិនិត្យសំណើនៅនឹងកន្លែងជាមួយនោះ ។ តំលៃនៃការបញ្ជូនទិន្នន័យ ត្រូវចេញដោយរដ្ឋភាគីនោះ ។

លក្ខខណ្ឌទាំងឡាយ ដែលតាមលក្ខខ័ណ្ឌនោះ ឧបករណ៏ទាំងនោះបានផ្តល់ទិន្នន័យបន្ថែមអោយហើយតាមលក្ខខណ្ឌនោះដែរ មជ្ឈមណ្ឌលទិន្នន័យអន្តរជាតិ ស្នើសុំការផ្សព្វផ្សាយបន្ថែម ឬការបញ្ជាក់បំភ្លឺត្រូវលំអិតក្នុងស្ទូនប្រតិបត្តិការរបស់បណ្តាញត្រួតពិនិត្យពាក់ព័ន្ធ ។

## គ-ការពិគ្រោះយោបល់ និង ការបញ្ជាក់បំភ្លឺ

២៩-ដោយគ្មានការប៉ះពាល់ដល់សិទ្ធិនៃរាល់រដ្ឋភាគីនីមួយៗ ក្នុងការស្នើសុំត្រួតពិនិត្យនៅនឹងកន្លែងរដ្ឋភាគីទាំងអស់គ្រប់ពេល ដែលមានលទ្ធភាពត្រូវជាជំហានដំបូងព្យាយាមស្រាយបំភ្លឺ និងដោះស្រាយរវាងគ្នានិងគ្នាឬជាមួយឬតាមរយៈអង្គការ នូវបញ្ហាទាំងឡាយណាដែលអាចជាមូលហេតុនាំទៅដល់ការមិនប្រព្រឹត្តិតាមកាតព្វកិច្ចជាមូលដ្ឋាននៃសន្ធិសញ្ញានេះ ។

៣០-រដ្ឋជាភាគី ដែលទទួលសំណើផ្ទាល់ពីរដ្ឋជាភាគីដ៏ទៃទៀតស្របតាមកថាខ័ណ្ឌ ២៩ ត្រូវផ្តល់ការបកស្រាយបំភ្លឺទៅរដ្ឋជាភាគីធ្វើសំណើអោយបានឆាប់តាមតែអាចធ្វើទៅបាន ប៉ុន្តែក្នុងគ្រប់កាលៈទេសៈទាំងអស់មិនអោយយឺតជាង ៤៨ ម៉ោង ក្រោយពីការស្នើសុំ ។ ទាំងរដ្ឋជាភាគីធ្វើសំណើ និងទទួលសំណើអាចជូនព័តមានអំពីសំណើ និងការឆ្លើយតបទៅក្រុមប្រឹក្សាប្រត្តបត្តិ និង អគ្គនាយក ។

៣១-រដ្ឋជាភាគី ត្រូវមានសិទ្ធិធ្វើសំណើទៅអគ្គនាយកអោយជួយក្នុងការស្រាយបំភ្លឺបញ្ហាមួយចំនួនដែលអាចជាមូលហេតុនាំទៅដល់ការមិនប្រព្រឹត្តិតាមកាតព្វកិច្ចជាមូលដ្ឋាននៃសន្ធិសញ្ញានេះ ។ អគ្គនាយកត្រូវផ្តល់ព័តមានពាក់ព័ន្ធក្រោមការត្រួតពិនិត្យរបស់លេខាដ្ឋានបច្ចេកទេស ដែលមានទំនាក់ទំនងក្នុងការទទួលខុសត្រូវលើសន្ធិសញ្ញា ។ អគ្គនាយកត្រូវជូនពត៌មានដល់ក្រុមប្រឹក្សាប្រតិបត្តិអំពីសំណើ និងពត៌មានដែលផ្តល់អោយទុកជាការឆ្លើយតប ប្រសិនបើមានសំណើពីរដ្ឋជាភាគីធ្វើសំណើ ។

៣២-រដ្ឋជាភាគីត្រូវមានសិទ្ធិធ្វើសំណើទៅក្រុមប្រឹក្សាប្រតិបត្តិ ដើម្បីទទួលបាននូវការបកស្រាយបំភ្លឺពីរដ្ឋជាភាគីដ៏ទៃទៀត អំពីបញ្ហាទាំងឡាយណា ដែលអាចជាមូលហេតុនាំទៅដល់ការមិនប្រព្រឹត្តិតាមកាតព្វកិច្ចជាមូលដ្ឋាននៃសន្ធិសញ្ញានេះ ។ ក្នុងករណីដូច្នេះ ត្រូវអនុវត្តដូចតទៅ :

ក-ក្រុមប្រឹក្សាប្រតិបត្តិ ត្រូវបញ្ជូនសំណើអំពីការបកស្រាយបំភ្លឺទៅរដ្ឋជាភាគីទទួលសំណើតាមរយៈអគ្គនាយកមិនអោយលើសពី ២៤ ម៉ោង បន្ទាប់ពីទទួលសំណើ ។

ខ-រដ្ឋភាគីទទួលសំណើត្រូវផ្តល់ការបកស្រាយបំភ្លឺ ( clarification ) ទៅក្រុមប្រឹក្សាប្រតិបត្តិអោយបានឆាប់តាមតែអាចធ្វើទៅបាន ក៏ប៉ុន្តែក្នុងករណីណាក៏ដោយមិនអោយយឺតជាង ៤៨ ម៉ោង បន្ទាប់ពីបានទទួលសំណើ ។

គ-ក្រុមប្រឹក្សាប្រតិបត្តិត្រូវទទួលការដឹងឮអំពីការបកស្រាយបំភ្លឺ និងបញ្ជូនបន្តទៅរដ្ឋភាគីធ្វើសំណើមិនអោយយឺតជាង ២៤ ម៉ោងបន្ទាប់ពីបានទទួលវា ។

ឃ-ក្នុងករណី រដ្ឋធ្វើសំណើគិតថា ការបកស្រាយមិនគ្រប់គ្រាន់វាមានសិទ្ធិស្នើទៅក្រុមប្រឹក្សាប្រតិបត្តិ ដើម្បីទទួលការបកស្រាយបំភ្លឺបន្ថែមទៀតពីរដ្ឋភាគីទទួលសំណើ ។ ក្រុមប្រឹក្សាប្រតិបត្តិ ត្រូវជូនពត៌មានដោយគ្មានការពន្យាពេលទៅរដ្ឋភាគីទាំងអស់រាល់សំណើដែលទាក់ទងដល់ការបកស្រាយបំភ្លឺស្របទៅតាមកថាខណ្ឌនេះ ក៏ដូចជាការឆ្លើយតបដែលផ្ទាល់ដោយរដ្ឋភាគីទទួលសំណើ ។

៣៣-ក្នុងករណីរដ្ឋភាគីធ្វើសំណើយល់ថា ការបកស្រាយបំភ្លឺ ដែលទទួលបានក្រោមកថាខណ្ឌ ៣២ ( ឃ ) មិនបំពេញតាមតំរូវការរដ្ឋនោះមានសិទ្ធិស្នើកោះហៅប្រជុំក្រុមប្រឹក្សាប្រតិបត្តិដែលក្នុងកិច្ចប្រជុំនោះ រដ្ឋភាគីដែលមានទំនាក់ទំនងផ្ទាល់ ហើយដែលមិនមែនជាសមាជិកនៃក្រុមប្រឹក្សាប្រតិបត្តិមានសិទ្ធិពេញលេញអាចចូលរួមបាន ។ ក្នុងកិច្ចប្រជុំបែបនេះ ក្រុមប្រឹក្សាប្រតិបត្តិ ត្រូវពិនិត្យលើបញ្ហានានា និងអាចបញ្ជាអោយចាត់វិធានការផ្សេងៗស្របទៅតាមមាត្រាទី ៨ ។

## ឃ_ការត្រួតពិនិត្យនៅនឹងកន្លែង សំណើសំរាប់ការត្រួតពិនិត្យនៅនឹងកន្លែង

៣៤-រដ្ឋភាគីនីមួយៗ មានសិទ្ធិធ្វើសំណើលើការត្រួតពិនិត្យនៅនឹងកន្លែងស្របទៅតាមបទបញ្ញត្តិទាំងឡាយនៃមាត្រានេះ និងផ្នែកទី ២ នៃពិធីសារក្នុងទឹកដី ឬលើទីកន្លែងដ៏ទៃផ្សេងដែលស្ថិតនៅក្រោមអំណាច ឬការត្រួតត្រារបស់រដ្ឋភាគី ។

៣៥-គោលបំណងតែមួយគត់នៃការត្រួតពិនិត្យនៅនឹងកន្លែង គឺដើម្បីបកស្រាយបំភ្លឺថាតើការផ្ទុះដោយសារការសាកល្បងអាវុធនុយក្លេអ៊ែ ឬការផ្ទុះជាតុនុយក្លេអ៊ែរផ្សេងទៀតបានធ្វើដោយបំពានលើមាត្រាទី ១ និង ដើម្បីប្រមូលតាមលទ្ធភាពដែលអាចធ្វើបាននូវរាល់ហេតុការណ៏ទាំងឡាយដើម្បីជួយកំនត់ចំនួនអ្នកទាំងឡាយណា ដែលអាចប្រព្រឹត្តិរំលោភលើច្បាប់ទាំងនេះ ។

៣៦-រដ្ឋភាគីដាក់សំណើ ត្រូវប្រកាន់ខ្ជាប់នូវសំណើ . នៃការត្រួតពិនិត្យនៅនឹងកន្លែងក្រោមវិសាលភាពនៃសន្ធិសញ្ញានេះ និងផ្តល់ពត៌មាននៅក្នុងសំណើស្របតាមកថាខណ្ឌ ៣៧ ។ រដ្ឋភាគីដាក់សំណើត្រូវចៀសវាងនូវសំណើនៃការត្រួតពិនិត្យ ដែលគ្មានមូលដ្ឋានត្រឹមត្រូវ ឬជាការប្រមាថ ។

៣៧-ការស្នើសុំត្រួតពិនិត្យនៅនឹងកន្លែង ត្រូវបានបង្កើតឡើងដោយឈរលើមូលដ្ឋាននៃពត៌មាន ដែលប្រមូលបានមកពីប្រពន្ធ័ត្រួតពិនិត្យអន្តរជាតិលើពត៌មានបច្ចេកទេសសមស្រប ដែលទទួលបានពីការត្រួតពិនិត្យដោយប្រពន្ធ័បច្ចេកទេសជាតិក្នុងកំរិតមួយ ដែលប្រព្រឹត្តិតាមគោលការណ៍ ដែលបានទទួលស្គាល់ជាទូទៅនៃច្បាប់អន្តរជាតិ ឬពីការរួមផ្សំនៃប្រព័ន្ធខាងលើ ។ ការស្នើសុំត្រូវមានពត៌មានស្របតាមផ្នែក II កថាខណ្ឌ ៤១ នៃពិធីសារ ។

៣៨-រដ្ឋភាគីដាក់សំណើត្រូវបង្ហាញសំណើនៃការត្រួតពិនិត្យនៅនឹងកន្លែងដល់ក្រុមប្រឹក្សាប្រតិបត្តិ និងដល់អគ្គនាយកក្នុងពេលតែមួយ ដើម្បីអគ្គនាយកចាប់ផ្តើមដំណើរការនីតិវិធីជាបន្ទាន់ ។

## វិធានការជាបន្តទៀត បន្ទាប់ពីមានការដាក់សំណើត្រួតពិនិត្យនៅនឹងកន្លែង

៣៩-ក្រុមប្រឹក្សាប្រតិបត្តិ ត្រូវចាប់ផ្តើមការពិចារណាជាបន្ទាន់ បន្ទាប់ពីបានទទួលសំណើត្រួតពិនិត្យនៅនឹងកន្លែងរួចមក ។

៤០-អគ្គនាយក ក្រោយពីទទួលសំណើនៃការត្រួតពិនិត្យនៅនឹងកន្លែង ត្រូវប្រាប់ដំណឹងអំពីការទទួលសំណើនេះទៅរដ្ឋភាគីវិញក្នុងរវាង ២ ម៉ោង និងផ្សព្វផ្សាយសំណើទៅរដ្ឋភាគីថា ត្រូវបានត្រួតពិនិត្យក្នុងរវាង ៦ ម៉ោង ។ អគ្គនាយក ត្រូវបញ្ជាក់អោយច្បាស់ថា សំណើនេះសមស្របតាមលក្ខខណ្ឌដូចចែងក្នុងផ្នែកទី II កថាខ័ណ្ឌ ៤១ នៃពិធីសារ និងបើចាំបាច់ត្រូវជួយដល់រដ្ឋភាគីដាក់សំណើក្នុងការបំពេញបែបបទសំណើអោយបានសមស្រប នឹងផ្សព្វផ្សាយសំណើនេះទៅក្រុមប្រឹក្សាប្រតិបត្តិ និងទៅរដ្ឋភាគីដ៏ទៃទៀតទាំងអស់ក្នុងរយៈ ២៤ ម៉ោង ។

៤១-នៅពេលមានសំណើនៃការត្រួតពិនិត្យនៅនឹងកន្លែងសមស្របតាមលក្ខខណ្ឌទាំងនោះ លេខាធិការដ្ឋានបច្ចេកទេស ត្រូវចាប់ផ្តើមធ្វើការរៀបចំសំរាប់ការត្រួតពិនិត្យនៅនឹងកន្លែងដោយគ្មានពន្យារពេលឡើយ ។

៤២-អគ្គនាយក នៅពេលទទួលនូវសំណើនៃការត្រួតពិនិត្យនៅនឹងកន្លែង ស្ថិតនៅចំកន្លែងត្រួតពិនិត្យដែលស្ថិតនៅក្រោមច្បាប់ ឬការត្រួតពិនិត្យរបស់រដ្ឋភាគី ត្រូវទាមទារអោយមានការបកស្រាយបំភ្លឺជាបន្ទាន់ពីរដ្ឋភាគីដែលចង់បានការត្រួតពិនិត្យ ដើម្បីបញ្ជាក់បំភ្លឺ និងដោះស្រាយបញ្ហាដែលលើកឡើងក្នុងសំណើ ។

៤៣-រដ្ឋភាគីដែលទទួលសំណើអោយស្រាយបំភ្លឺស្របតាមកថាខណ្ឌ ៤២ ត្រូវផ្តល់ដល់អគ្គនាយក នូវការពន្យល់ និងពត៌មានពាក់ព័ន្ធដ៏ទៃផ្សេងទៀតអោយបានឆាប់តាមតែអាចធ្វើទៅបាន ប៉ុន្តែមិនត្រូវយឺតជាង ៧២ ម៉ោង បន្ទាប់ពីបានទទួលសំណើអោយស្រាយបំភ្លឺនោះឡើយ ។

៤៤-មុននឹងក្រុមប្រឹក្សាប្រតិបត្តិធ្វើការសំរេចលើសំណើនៃការត្រួតពិនិត្យនៅនឹងកន្លែង អគ្គនាយក ត្រូវបញ្ជូនជាបន្ទាន់នូវពត៌មានបន្ថែមនានា ដែលទទួលបានពីប្រពន្ធ័ត្រួតពិនិត្យអន្តរជាតិ ឬដែលបានផ្តល់ដោយរដ្ឋភាគីនានា ដែលទាក់ទងនឹងព្រឹត្តិការណ៍ដូចបញ្ជាក់ក្នុងសំណើដោយរាប់ទាំងការស្រាយបំភ្លឺ ដែលបានផ្តល់ស្របតាមកថាខណ្ឌ ៤២ និង ៤៣ ដូចជាពត៌មានដទៃទៀត បានពីលេខាធិការដ្ឋានបច្ចេកទេស ដែលអគ្គនាយកគិតថាមានការពាក់ពន្ធ័ ឬក៏ត្រូវបានស្នើដោយក្រុមប្រឹក្សាប្រតិបត្តិ ។

៤៥-លុះត្រាតែរដ្ឋភាគីដាក់សំណើមិនគិតថា បញ្ហាដែលលើកឡើងក្នុងសំណើការត្រួតពិនិត្យនៅនឹងកន្លែងទុកត្រូវបានដោះស្រាយ ហើយរដ្ឋភាគីនោះបានលុបសំណើនោះវិញ ទើបក្រុមប្រឹក្សាប្រតិបត្តិធ្វើការសំរេចលើសំណើនោះ ដោយអនុលោមតាមកថាខណ្ឌ ៤៦ ។

## សេចក្តីសំរេចចិត្ត របស់ក្រុមប្រឹក្សាប្រតិបត្តិ

៤៦-បន្ទាប់ពីបានទទួលសំណើពីរដ្ឋភាគីដាក់សំណើ ក្រុមប្រឹក្សាប្រតិបត្តិ ត្រូវធ្វើការសំរេចលើសំណើនៃការត្រួតពិនិត្យនៅនឹងកន្លែងមិនអោយយឺតជាង ៩៦ ម៉ោងឡើយ ។ សេចក្តីសំរេចអនុមត័លើការត្រួតពិនិត្យនៅនឹងកន្លែង ត្រូវបានធ្វើឡើងយ៉ាងហោចណាស់ដោយសំលេងគាំទ្រ ៣០ នៃសមាជិកទាំងអស់នៃក្រុមប្រឹក្សាប្រតិបត្តិ ។ ប្រសិនបើក្រុមប្រឹក្សាប្រតិបត្តិមិនអនុមត័លើការត្រួតពិនិត្យទេ ការរៀបចំទាំងឡាយត្រូវបានបញ្ឈប់ភ្លាម និងគ្មានសកម្មភាពណាមួយទាក់ទងនឹងសំណើត្រូវបានធ្វើបន្តទៅទៀតឡើយ ។

៤៧-ដោយមិនយឺតជាង ២៥ ថ្ងៃ ក្រោយការអនុមត័លើការត្រួតពិនិត្យនៅនឹងកន្លែងស្របតាមកថាខណ្ឌ ៤៦ ក្រុមការងារត្រួតពិនិត្យ ត្រូវបញ្ជូនរបាយការណ៍នៃដំណើរការត្រួតពិនិត្យទៅក្រុមប្រឹក្សាប្រតិបត្តិតាមរយៈអគ្គនាយក ។ កិច្ចបន្តនៃការត្រួតពិនិត្យ ត្រូវចាត់ទុកថាបានអនុមត័ដរាបណាក្នុងរយៈពេលមិនយឺតជាង ៧២ ម៉ោង ក្រោយការទទួលរបាយការណ៍នៃដំណើរការត្រួតពិនិត្យ ក្រុមប្រឹក្សាប្រតិបត្តិមិនបានសំរេចដោយសំលេងភាគច្រើន នៃសមាជិករបស់ខ្លួនមិនអោយបន្តការត្រួតពិនិត្យតទៅទៀត ។ ក្នុងករណីដែលក្រុមប្រឹក្សាប្រតិបត្តិសំរេចមិនអោយបន្តការត្រួតពិនិត្យតទៅទៀតនោះ ការត្រួតពិនិត្យត្រូវបញ្ចប់ ហើយក្រុមអធិការកិច្ចត្រូវចាកចេញពីតំបន់ត្រួតពិនិត្យ និងទឹកដីនៃរដ្ឋភាគីផ្តល់ការត្រួតពិនិត្យអោយបានឆាប់តាមតែអាចធ្វើទៅបានស្របតាមផ្នែកទី II កថាខណ្ឌ ១០៩ និង ១១០ នៃពិធីសារ ។

៤៨-ក្នុងដំណើរការត្រួតពិនិត្យនៅនឹងកន្លែង ក្រុមអធិការកិច្ចអាចលើកសំណើទៅក្រុមប្រឹក្សាប្រតិបត្តិតាមរយៈអគ្គនាយក ។ ក្រុមប្រឹក្សាប្រតិបត្តិ ត្រូវធ្វើការសំរេចលើសំណើទាំងនោះ

មិនអោយយឺតជាង ៧២ ម៉ោង បន្ទាប់ពីបានទទួលសំណើ ។ សេចក្តីសំរេចលើការអនុមត័ត្រូវធ្វើឡើងដោយសំលេងភាគច្រើននៃសមាជិកក្រុមប្រឹក្សាប្រតិបត្តិ ។

៤៩-ក្រុមអធិការកិច្ច អាចស្នើក្រុមប្រឹក្សាប្រតិបត្តិតាមរយៈ អគ្គនាយកបន្ថែមការបន្តត្រួតពិនិត្យច្រើនបំផុត ៧០ ថ្ងៃ លើអាណត្តិ ៦០ ថ្ងៃ ដូចចែងក្នុងផ្នែក II កថាខណ្ឌ ៤ នៃពិធីសារប្រសិនបើ ក្រុមអធិការកិច្ចយល់ថាការបន្ថែមនោះ ភាចាំបាច់ដើម្បីអោយខ្លួនអាចបំពេញមុខងាររបស់ខ្លួនបាន ។ ក្រុមអធិការកិច្ច ត្រូវគូសបញ្ជាក់នៅក្នុងសំណើរបស់ខ្លួន នូវសកម្មភាពអ្វីខ្លះនិងវិធីបែបណាខ្លះ ដែលខ្លួនមានបំណងយកទៅអនុវត្តក្នុងកំឡុងរយៈពេលនៃការបន្ថែមបន្តការត្រួតពិនិត្យ ។ ក្រុមប្រឹក្សាប្រតិបត្តិ ត្រូវធ្វើការសំរេចលើសំណើនៃការបន្ថែមនេះមិនអោយយឺតជាង ៧២ ម៉ោងក្រោយទទួលសំណើ ។ សេចក្តីសំរេចលើការអនុមត័ដល់ការបន្ថែមបន្តការត្រួតពិនិត្យ ត្រូវបានធ្វើដោយសំលេងភាគច្រើននៃសមាជិកក្រុមប្រឹក្សាប្រតិបត្តិ ។

៥០-ក្រុមអធិការកិច្ចអាចធ្វើអនុសាសន៏បញ្ឈប់ការត្រួតពិនិត្យ ទៅក្រុមប្រឹក្សាប្រតិបត្តិតាមរយៈអគ្គនាយកបានគ្រប់ពេល បន្ទាប់ពីមានការអនុមត័លើការបន្តការត្រួតពិនិត្យនៅនឹងកន្លែងស្របទៅតាមកថាខណ្ឌ ៤៧ ។ អនុសាសន៏នោះ ត្រូវបានចាត់ទុកជាអនុមត័ បើក្នុងរយៈពេលមិនយឺតជាង ៧២ ម៉ោង ក្រោយការទទួលអនុសាសន៏ ( recommandation ) ក្រុមប្រឹក្សាប្រតិបត្តិមិនធ្វើការសំរេចដោយសំលេងពីរភាគបី ( ២/៣ ) នៃសមាជិកទាំងអស់របស់ខ្លួន ដើម្បីបញ្ឈប់នូវការត្រួតពិនិត្យ ។ ក្នុងករណីមានការបញ្ឈប់ការត្រួតពិនិត្យ ក្រុមអធិការកិច្ចត្រូវចាកចេញពីតំបន់ត្រួតពិនិត្យ និងទឹកដីនៃរដ្ឋភាគីផ្តល់ការត្រួតពិនិត្យអោយបានឆាប់តាមតែអាចធ្វើទៅបានស្របតាមផ្នែក ទី II កថាខណ្ឌ ១០៩ និង ១១០ នៃពិធីសារ ។

៥១-រដ្ឋភាគីដាក់សំណើ និងរដ្ឋភាគីត្រូវសុំអោយមានការត្រួតពិនិត្យ អាចចូលរួមក្នុងការពិភាក្សារបស់ក្រុមប្រឹក្សាប្រតិបត្តិអំពីសំណើនៃការត្រួតពិនិត្យនៅនឹងកន្លែងតែគ្មានសំលេង ក្នុងការបោះឆ្នោតទេ ។ រដ្ឋភាគីដាក់សំណើ និងរដ្ឋភាគីត្រួតពិនិត្យ ក៏អាចចូលរួមក្នុងរាល់ការពិភាក្សាជាបន្តបន្ទាប់របស់ក្រុមប្រឹក្សាប្រតិបត្តិ ដែលទាក់ទងនឹងការត្រួតពិនិត្យដោយគ្មានសំលេង ក្នុងការបោះឆ្នោតផងដែរ ។

៥២-អគ្គនាយក ត្រូវជូនដំណឹងដល់គ្រប់រដ្ឋភាគីទាំងអស់ក្នុងរវាង ២៤ ម៉ោង អំពីការសំរេចណាមួយនិងរបាយការណ៍ផ្សេងៗ សំណើផ្សេងៗ និងអនុសាសន៏ទាំងឡាយទៅក្រុមប្រឹក្សាប្រតិបត្តិដោយអនុលោមតាមកថាខណ្ឌ ៤៦ ដល់ ៥០ ។

# វិធានការបន្តទៀត បន្ទាប់ពីការអនុមតិ នៃក្រុមប្រឹក្សាប្រតិបត្តិ លើការត្រួតពិនិត្យ នៅនឹងកន្លែង

៤៣-ក្រុមអធិការកិច្ច ដែលតែងតាំងដោយអគ្គនាយក និងស្របទៅតាមបញ្ញត្តិទាំងឡាយនៃសន្ធិសញ្ញា និងពិធីសារ ត្រូវដឹកនាំការត្រួតពិនិត្យនៅនឹងកន្លែង ដែលបានអនុមត័ដោយក្រុមប្រឹក្សាប្រតិបត្តិ និងដោយគ្មានការពន្យារពេលឡើយ ។ ក្រុមអធិការកិច្ចត្រូវទៅដល់ចំនុចច្រកទ្វារចេញចូលរដ្ឋនោះមិនអោយយឺតជាង ៦ ថ្ងៃ បន្ទាប់ពីក្រុមប្រឹក្សាប្រតិបត្តិបានទទួលសំណើនៃការត្រួតពិនិត្យនៅនឹងកន្លែងពីរដ្ឋភាគីដាក់សំណើ ។

អគ្គនាយក ត្រូវចេញអាណត្តិនៃការត្រួតពិនិត្យសំរាប់ការធ្វើការត្រួតពិនិត្យនៅនឹងកន្លែង។ អាណត្តិនៃការត្រួតពិនិត្យ ត្រូវបញ្ចូលនូវពត៌មានដូចមានចែងក្នុងផ្នែក II កថាខ័ណ្ឌ ៤២ នៃពិធីសារ ។

៤៥-អគ្គនាយក ត្រូវជូនដំណឹងទៅរដ្ឋភាគី ស្តីពីផ្តល់ការត្រួតពិនិត្យមិនអោយយឺតជាង ២៤ ម៉ោង មុនពេលការកំណត់មកដល់របស់ក្រុមអធិការកិច្ចនៅត្រង់ចំនុចច្រកទ្វារចេញចូលប្រទេសនោះ (at the point of entry) ស្រមទៅតាមកថាខ័ណ្ឌ ៤៣ ផ្នែកទី II នៃពិធីសារ ។

## ការត្រួតពិនិត្យនៅនឹងកន្លែង

៤៦-យោងតាមបទបញ្ញត្តិនៃសន្ធិសញ្ញានេះ និងពិធីសារ រដ្ឋនិមួយៗត្រូវអនុញ្ញាតអោយអង្គការធ្វើការត្រួតពិនិត្យនៅនឹងកន្លែងនៅលើទឹកដីរបស់ខ្លួន ឬនៅនឹងកន្លែងទាំងឡាយ ដែលឋិតនៅក្រោមយុត្តិធិការនិងការគ្រប់គ្រងរបស់ខ្លួន។ ទោះជាយ៉ាងណាក៏ដោយ ក៏គ្មានរដ្ឋជាភាគីណាមួយត្រូវបានលើកលែងលើករណីដូចគ្នានេះទេ ។

៤៧-អនុលោមទៅតាមបទដ្ឋានផ្សេងៗនៅក្នុងសន្ធិសញ្ញា និងពិធីសារនេះ រដ្ឋភាគីត្រូវត្រួតពិនិត្យមាន :

ក-សិទ្ធិ និងកាតព្វកិច្ចផ្តល់នូវការជួយជ្រោមជ្រែងសមស្របទាំងឡាយ ដើម្បីអនុវត្តតាមសន្ធិសញ្ញានេះនៅក្នុងទិសដៅ ដើម្បីអោយក្រុមអធិការកិច្ចបំពេញអាណត្តិរបស់គេ ។

ខ-សិទ្ធិចាត់វិធានការនានា បើសិនយល់ថាជាការចាំបាច់ ដើម្បីការពារផលប្រយោជន៍សន្តិសុខជាតិនិងបង្ការការផ្សព្វផ្សាយពត៌មានសំងាត់ដែលមិនទាក់ទងទៅនឹងទិសដៅអធិការកិច្ច ។

គ-កាតព្វកិច្ច ផ្ដល់ការអនុញ្ញាតចូលក្នុងតំបន់អធិការកិច្ច សំរាប់គោលដៅតែមួយគត់ក្នុងការកំណត់ហេតុការណ៍ ដែលទាក់ទងទៅនឹងគោលដៅនៃការធ្វើអធិការកិច្ចដូចមានចែងនៅក្នុងកថាខណ្ឌរង ខ និងកាតព្វកិច្ចសមស្របតាមច្បាប់ទាំងឡាយដែល អាចយល់ឃើញថាជាសិទ្ធិគ្រប់គ្រង ឬការផែកផេរ និងការរើបម្លាស់ដោយសមស្រប ។

ឃ-កាតព្វកិច្ចដោយសំអាងទៅលើកថាខណ្ឌនេះ ឬជំពូក២ កថាខណ្ឌទី ៨៨ នៃពិធីសារ ដើម្បីលាក់បាំងនៃការរំលោភកាតព្វកិច្ចទាំងឡាយមានចែងក្នុងមាត្រាទី ១ នោះឡើយ ។

ង-កាតព្វកិច្ចមិនរារាំងដល់សមត្ថភាពនៃក្រុមអធិការកិច្ច ក្នុងការធ្វើសកម្មភាពក្នុងតំបន់ដើម្បីអនុវត្តសកម្មភាពរបស់គេ យោងទៅតាមសន្ធិសញ្ញា និងពិធីសារ ។

នៅក្នុងបរិបទការធ្វើអធិការកិច្ចដល់កន្លែងការចូល ( ACCESS ) មានន័យថា ទាំងការចូលរបស់ក្រុមអធិការកិច្ចព្រមទាំងឧបករណ៍សំភារៈ និងដំណើរការសកម្មភាពអធិការកិច្ចនៅក្នុងតំបន់ដែលត្រូវធ្វើអធិការកិច្ច ។

៥៨-ដោយសមស្របតាមលទ្ធភាពនិងពេលវេលានៃការអនុវត្តន៍អាណត្តិ នៃការធ្វើអធិការកិច្ចនិងយោងទៅតាមនីតិវិធីនៃពិធីសារ ដែលបានចែងពីការធ្វើអធិការកិច្ចនៅនឹងកន្លែងត្រូវប្រព្រឹត្តិទៅដោយមានលក្ខណៈប៉ះពាល់តិចបំផុត ។ កន្លែងណាក៏ដោយក្រុមអធិការកិច្ចត្រូវចាប់ផ្ដើមដោយនីតិវិធីប៉ះពាល់តិចបំផុត និងអាចដោយនីតិវិធីបង្ខំបានដោយយល់ថាជាការចាំបាច់ ដើម្បីប្រមូលពត៌មានឱ្យបានគ្រប់គ្រាន់ ដើម្បីបញ្ជាក់ពីបញ្ហាមិនអនុវត្តតាមសន្ធិសញ្ញា ។

ក្រុមអធិការកិច្ចត្រូវស្វែងរកពត៌មាន និងទិន្នន័យចាំបាច់ ដើម្បីគោលដៅអធិការកិច្ច នឹងត្រូវបន្ថយជាអប្បបរិមា នូវការជ្រៀតជ្រែកក្នុងដំណើរការជាប្រក្រតីរបស់រដ្ឋភាគីទទួលអធិការកិច្ច ។

៥៩-រដ្ឋភាគីទទួលអធិការកិច្ច ត្រូវជួយដល់ក្រុមអធិការកិច្ច ទាំងការធ្វើអធិការកិច្ចនៅនឹងកន្លែងនិងជួយសំរួលការងាររបស់ពួកគេ ។

៦០-អនុលោមទៅតាមជំពូក ២ កថាខណ្ឌ ៨៦ ដល់ ៩៦ នៃពិធីសារ បើសិនជាភាគីទទួលអធិការកិច្ចដាក់កំរិតការចូលទៅក្នុងតំបន់អធិការកិច្ចរដ្ឋនោះ ត្រូវខិតខំពិភាក្សាជាមួយក្រុមអធិការកិច្ចរិះរកមធ្យោបាយផ្សេងទៀត ដែលសមស្របតាមសន្ធិសញ្ញានេះ ។

ទាំងឡាយក្នុងរយៈពេល ៤៨ ម៉ោង នឹងកំណត់ពត៌មាន និងទិន្នន័យ ដែលមិនពាក់ពន្ធ័ទៅនឹងគោលដៅនៃការធ្វើអធិការកិច្ច ដែលមិនត្រូវផ្សព្វផ្សាយក្រៅពីរង្វង់លេខាធិការដ្ឋានបច្ចេកទេស ។

អគ្គនាយក ត្រូវពិចារណាលើសំណើកែប្រែទាំងឡាយ ចំពោះសេចក្តីព្រាងរបាយការណ៍នៃការធ្វើអធិការកិច្ច ដែលធ្វើឡើងដោយរដ្ឋភាគីទទួលអធិការកិច្ច ។ ក្នុងករណីដែលអាចធ្វើបាន អគ្គនាយកត្រូវកត់ករណីនេះ ចូលទៅក្នុងរបាយការណ៍ ។

អគ្គនាយក ត្រូវភ្ជាប់នឹងរបាយការណ៏នេះផងដែរ នូវការអធិប្បាយ និងពន្យល់ទាំងឡាយ ដែលផ្តល់ដោយភាគីរដ្ឋទទួលអធិការកិច្ច ។

៦៤-អគ្គនាយក ត្រូវបញ្ជូនជាបន្ទាន់នូវរបាយការណ៏ធ្វើអធិការកិច្ចទៅរដ្ឋភាគីដាក់សំណើរដ្ឋភាគីទទួលធ្វើអធិការកិច្ច ក្រុមប្រឹក្សាប្រតិបត្តិ និងទៅរដ្ឋភាគីផ្សេងៗទៀត ។

អគ្គនាយក ត្រូវបញ្ជូនតទៅទៀតយ៉ាងរហ័សទៅកាន់ក្រុមប្រឹក្សាប្រតិបត្តិ និងរាល់ភាគីផ្សេងៗនូវលទ្ធផលនៃការវិភាគពិនិត្យ នៅក្នុងទីពិសោធន៏ស្របទៅតាមជំពូក ២ កថាខ័ណ្ឌ ១០ នៃពិធីសារទិន្នន័យពាក់ព័ន្ធ ដែលបានពីប្រព័ន្ធត្រួតពិនិត្យអន្តរជាតិ ការថ៉ាន់ស្មានរបស់រដ្ឋភាគីដាក់សំណើ និងទទួលធ្វើអធិការកិច្ចព្រមទាំងពត៌មានទាំងឡាយ ដែលអគ្គនាយកយល់ឃើញថាមានការពាក់ព័ន្ធ ។ ក្នុងករណីមានការជឿនលឿនលើផ្នែកអធិការកិច្ច ដូចមានចែងក្នុងកថាខ័ណ្ឌ ទី ៤៧ អគ្គនាយកត្រូវបញ្ជូនរបាយការណ៏ទៅក្រុមប្រឹក្សាប្រតិបត្តិនៅក្នុងកាលបរិច្ឆេទពេលវេលា ដែលកំណត់បញ្ជាក់នៅក្នុងកថាខ័ណ្ឌនោះ ។

៦៥-ស្របតាមអំណាច និងតួនាទីរបស់ខ្លួន ក្រុមប្រឹក្សាប្រតិបត្តិ ត្រូវពិនិត្យសាជាថ្មី នូវរបាយការណ៏អធិការកិច្ច និងសម្ភារៈនានា ដែលបានផ្តល់ដូចចែង ក្នុងកថាខ័ណ្ឌទី ៦៤ និងត្រូវលើកពីបញ្ហាព្រួយបារម្ភទាំងឡាយដូចជា :

ក-តើមានការកើតឡើង ការមិនអនុវត្តតាមសន្ធិសញ្ញា ឬទេ ?

ខ-តើមានការរំលោភលើសិទ្ធិ ស្នើត្រួតពិនិត្យនៅនឹងកន្លែងដែរ ឬទេ ? ។

៦៦-ប្រសិនបើ ក្រុមប្រឹក្សាប្រតិបត្តិធ្វើការសន្និដ្ឋានសមស្របតាមអំណាច និងតួនាទីរបស់ខ្លួនថាចាំបាច់ត្រូវមានសកម្មភាពបន្តទៅទៀត ដូចមានចែង ក្នុងកថាខ័ណ្ឌទី ៦៥ នោះ ក្រុមប្រឹក្សាប្រតិបត្តិ ត្រូវចាត់វិធានការសមស្របដូចមានចែងក្នុងមាត្រាទី ៥ ។

# អ្នកអង្កេតការណ៍

៦១-ចំពោះអ្នកអង្កេតការត្រូវអនុវត្តដូចតទៅ ៖

ក-យោងទៅតាមកិច្ចព្រមព្រៀងភាគីទទួលអធិការកិច្ចអាចបញ្ជូនតំណាងមួយនាក់ ដែលអាចជាសញ្ជាតិរបស់ភាគីដាក់សំណើ ឬសញ្ជាតិរដ្ឋទី ៣ ដើម្បីធ្វើការអង្កេតទៅលើដំណើរការនៃអធិការកិច្ចនៅនឹងកន្លែង ។

ខ-រដ្ឋភាគីទទួលអធិការកិច្ច ត្រូវជូនដំណឹងពីការយល់ព្រម ឬមិនយល់ព្រម នៃអ្នកអង្កេតការ ដែលគេស្នើទៅអគ្គនាយក ក្នុងរយៈពេល ១២ ម៉ោង បន្ទាប់ពីមានការយល់ព្រមអធិការកិច្ចនៅនឹងកន្លែងដោយក្រុមប្រឹក្សាប្រតិបត្តិ ។

គ-ក្នុងករណីយល់ព្រមភាគីទទួលអធិការកិច្ច ត្រូវផ្តល់ឱ្យអ្នកអង្កេតការណ៍ចូលទៅអង្កេតស្របតាមពិធីសារ ។

ឃ-ជាធម្មតារដ្ឋទទួលអធិការកិច្ចយល់ព្រមទទួលអធិការកិច្ចតែបើរដ្ឋនោះបដិសេធវិញហេតុការណ៍នោះ ត្រូវបានកត់ទុកនៅក្នុងរបាយការណ៍អធិការកិច្ច ។ មិនអនុញ្ញាតឱ្យមានលើសពីចំនួន ៣ នាក់ទេ ចំពោះអ្នកអង្កេតការណ៍មកពីរដ្ឋដាក់សំណើ ។

៦២-របាយការណ៍អធិការកិច្ចត្រូវមាន ៖

ក-ការអធិប្បាយនៃសកម្មភាពរបស់ក្រុមអធិការកិច្ចដែលបានអនុវត្ត ។

ខ-អង្គហេតុនៃក្រុមអធិការកិច្ច ដែលពាក់ពន្ធ័ទៅនឹងគោលដៅអធិការកិច្ច ។

គ-របាយការណ៍ អំពីសហប្រតិបត្តិការ ដែលបានអនុញ្ញាតក្នុងកំឡុងពេលអធិការកិច្ចនៅនឹងកន្លែង ។

ឃ-ពិពណ៌នាច្បាស់លាស់ ពីការអនុញ្ញាតអោយចូលធ្វើអធិការកិច្ច ដែលបានផ្តល់អោយរាប់បញ្ចូលទាំងមធ្យោបាយជំពីសផ្សេងៗទៀត ដែលបានផ្តល់ដល់ក្រុមអធិការកិច្ចក្នុងកំឡុងពេលធ្វើអធិការកិច្ចនៅនឹងកន្លែង ។

ង-និងធ្វើរបាយការណ៍លំអិតផ្សេងៗ ដែលពាក់ពន្ធ័ទៅនឹងគោលដៅធ្វើអធិការកិច្ច ។ ការអង្កេតដោយឡែកៗ របស់អ្នកធ្វើអធិការកិច្ចត្រូវភ្ជាប់ជាមួយរបាយការណ៍នេះដែរ ។

៦៣-អគ្គនាយក ត្រូវប្រគល់សេចក្តីព្រាងរបាយការណ៍ធ្វើអធិការកិច្ចដល់រដ្ឋទទួលធ្វើអធិការកិច្ចបានជ្រាប ។ រដ្ឋភាគីទទួលអធិការកិច្ច ត្រូវមានភារកិច្ចផ្តល់នូវការអធិប្បាយ និងការពន្យល់

## សំណើអធិការកិច្ចនៅលើកន្លែង ដែលចាត់ទុកជាការរំលោភ និង មិនសំខាន់

៦៧-ប្រសិនបើ ក្រុមប្រឹក្សាប្រតិបត្តិ បដិសេធការធ្វើអធិការកិច្ចនៅលើកន្លែងដោយឈរលើមូលដ្ឋានថា សំណើធ្វើអធិការកិច្ចនោះមិនសំខាន់ ឬជាការរំលោភ ឬការធ្វើអធិការកិច្ចត្រូវបញ្ឈប់ដោយសារមូលហេតុដូចខាងលើ ក្រុមប្រឹក្សាប្រតិបត្តិត្រូវពិចារណា និងសំរេចអនុវត្តវិធានការសមស្របដូចតទៅ ដើម្បីកែតំរូវស្ថានភាពនោះ :

ក-ទាមទារឱ្យរដ្ឋភាគីដាក់សំណើចេញថ្លៃសង នូវការរៀបចំទាំងឡាយ ដែលធ្វើឡើងដោយលេខាធិការដ្ឋានបច្ចេកទេស ។

ខ-បញ្ឈប់ជាបណ្តោះអាសន្ននូវសិទ្ធិរបស់រដ្ឋភាគីដាក់សំណើក្នុងការស្នើសុំត្រួតពិនិត្យនៅលើទីកន្លែងក្នុងកំឡុងពេលមួយ តាមការកំណត់របស់ក្រុមប្រឹក្សាប្រតិបត្តិ ។

គ-បញ្ឈប់ជាបណ្តោះអាសន្ន នូវសិទ្ធិរដ្ឋភាគីដាក់សំណើក្នុងការចូលរួមក្នុងក្រុមប្រឹក្សា-ប្រតិបត្តិក្នុងកំឡុងពេលមួយ ។

## ខ-វិធានការបង្កើតទំនុកចិត្ត

៦៨-ក-ដើម្បីរួមចំណែកដោះស្រាយបញ្ហា ដែលកើតឡើងពីការបកស្រាយមិនត្រឹមត្រូវនៃទិន្នន័យ ដែលទាក់ទងទៅនឹងការផ្ទុះគីមី និង

ខ-ដើម្បីឧបត្ថម្ភ កំណត់ទីតាំង នៃស្ថានីយ៍ដែលជាផ្នែកនៃបណ្តាញប្រពន្ធ័ត្រួតពិនិត្យអន្តរជាតិ រដ្ឋនីមួយៗមានភារកិច្ចសហប្រតិបត្តិការជាមួយអង្គការ និងរដ្ឋភាគីផ្សេងៗទៀត ក្នុងការអនុវត្តន៍វិធានការដែលពាក់ពន្ធ័ដូចមានចែងក្នុងជំពូក ៣ នៃពិធីសារ ។

## មាត្រា ៥

## វិធានការ ដើម្បីកែតំរូវស្ថានភាព
## និង ដើម្បីធានាការអនុវត្តន៍ រួមទាំងទណ្ឌកម្ម

១-ដោយផ្អែកលើការពិចារណាលើអនុសាសន៍នៃក្រុមប្រឹក្សាប្រតិបត្តិ សន្និសីទត្រូវចាត់វិធានការចាំបាច់ដូចបាន ចែងក្នុងកថាខណ្ឌទី ២ និងទី ៣ ដើម្បីធានាការអនុវត្តន៍សន្និសញ្ញា និងកែតំរូវស្ថានការណ៍ ដែលផ្ទុយនឹងបញ្ញត្តិនៃសន្និសញ្ញានេះ ។

២-ក្នុងករណីរដ្ឋភាគីណាមួយ បានស្នើដោយសន្និសីទ ឬក្រុមប្រឹក្សាប្រតិបត្តិ ដើម្បីកែតំរូវស្ថានភាព ដែលកើតមានបញ្ហាជាប់ទាក់ទងនឹងការអនុវត្តន៍ ហើយខកខានមិនបានបំពេញភារកិច្ចដែលបានកំណត់ពេលវេលាជាក់លាក់ សន្និសីទអាចសំរេចដាក់កំរិត ឬបញ្ឈប់ជាបណ្ដោះអាសន្នចំពោះរដ្ឋជាភាគី ពីការអនុវត្តន៍សិទ្ធិ និងអភ័យឯកសិទ្ធិក្នុងសន្និសញ្ញានេះ រហូតដល់សន្និសីទសំរេចផ្សេងពីនេះ ។

៣-ក្នុងករណីមានការខូចខាតដល់កម្មវត្ថុ និងគោលបំណងនៃសន្និសញ្ញានេះ អាចកើតចេញពីការមិនអនុវត្តន៍កាតព្វកិច្ចមូលដ្ឋាននៃសន្និសញ្ញានេះ សន្និសីទអាចណែនាំទៅរដ្ឋភាគីទាំងឡាយអោយចាត់វិធានការរួមសមស្របតាមច្បាប់អន្តរជាតិ ។

៤-ក្នុងករណីបន្ទាន់ ក្រុមប្រឹក្សាប្រតិបត្តិអាចលើកបញ្ហានេះដោយសន្និសីទ ឬរួមទាំងពត៌មានពាក់ព័ន្ធ និងការសន្និដ្ឋាននានា ជូនអង្គការសហប្រជាជាតិ ។

## មាត្រា ៦
## ដំណោះស្រាយជំលោះ

១-ជំលោះដែលអាចកើតមានឡើងទាក់ទងទៅនឹងការអនុវត្តន៍ ឬការបកស្រាយក្នុងសន្និសញ្ញានេះត្រូវដោះស្រាយសមស្របទៅតាមបទបញ្ញត្តិនានា នៃសន្និសញ្ញានេះ និងអនុលោមទៅតាមបទបញ្ញត្តិទាំងឡាយ នៃធម្មនុញ្ញសហប្រជាជាតិ ។

២-នៅពេលជំលោះកើតឡើងរវាងរដ្ឋភាគីពីរ ឬច្រើនដែលទាក់ទងទៅនឹងការអនុវត្តន៍ និងការបកស្រាយសន្និសញ្ញានេះ ភាគីពាក់ព័ន្ធត្រូវពិគ្រោះជាមួយគ្នាឈរលើទស្សនៈដោះស្រាយជំលោះ

ពិធីសារនោះបានផងដែរ ។ សំណើវិសោធនកម្ម ត្រូវអនុវត្តតាមលក្ខខ័ណ្ឌនៃនីតិវិធីនៅក្នុងកថាខណ្ឌទី ២ ដល់ទី ៦ ។ សំណើកែប្រែយោងទៅតាមកថាខណ្ឌ ៧ ត្រូវអនុវត្តតាមលក្ខខណ្ឌនីតិវិធីនៅក្នុងកថាខណ្ឌទី ៨ ។

២-សំណើវិសោធនកម្មត្រូវពិចារណា និងអនុមត័ដោយសន្និសីទវិសោធនកម្ម ។

៣-រាល់សំណើវិសោធនកម្ម ត្រូវបញ្ជូនទៅអគ្គនាយក ដើម្បីផ្សព្វផ្សាយសំណើនេះ ចំពោះរាល់រដ្ឋភាគីទាំងអស់ និងរដ្ឋតំកល់ទុកសន្ធិសញ្ញានេះ ព្រមទាំងសុំមតិពីរដ្ឋភាគីទាំងនោះ ថាតើសន្និសីទវិសោធនកម្មមួយ នឹងត្រូវកោះប្រជុំពិចារណាលើសំណើនោះដែរឬទេ ? ។ ប្រសិនបើរដ្ឋភាគី ភាគច្រើនជូនដំណឹងទៅ អគ្គនាយកមិនយូរជាង ៣០ ថ្ងៃ បន្ទាប់ពីការផ្សព្វផ្សាយនោះថាពួកគេគាំទ្រនូវសំណើអគ្គនាយក នឹងត្រូវកោះប្រជុំ សន្និសីទធ្វើវិសោធនកម្មមួយដែលរាល់រដ្ឋភាគីទាំងអស់ត្រូវបានអញ្ជើញចូលរួម ។

៤-សន្និសីទវិសោធនកម្មត្រូវប្រព្រឹត្តិទៅភ្លាមៗ បន្ទាប់ពីសម័យប្រជុំសាមញ្ញនៃសន្និសីទ ប្រសិនបើរដ្ឋភាគីទាំងអស់ ដែលគាំទ្រការកោះប្រជុំសន្និសីទវិសោធនកម្ម មិនស្នើអោយប្រជុំឆាប់ៗជាងនេះទេនោះ ។ ការធ្វើវិសោធនកម្មត្រូវប្រព្រឹត្តិទៅមិនលើសពី ៦០ ថ្ងៃ បន្ទាប់ពីការផ្សព្វផ្សាយដំណឹងសំណើវិសោធនកម្មនេះទេ ។

៥-ការធ្វើវិសោធនកម្ម ត្រូវអនុមត័យល់ព្រមដោយសន្និសីទវិសោធនកម្ម លើសំឡេងវិជ្ជមានភាគច្រើនរបស់រដ្ឋភាគីទាំងអស់ និងដោយគ្មានរដ្ឋភាគីណាមួយបោះឆ្នោតជំទាស់ឡើយ ។

៦-ការធ្វើវិសោធនកម្ម នឹងចូលជាធរមានចំពោះរដ្ឋភាគីទាំងអស់ ក្នុងរយៈពេល ៣០ ថ្ងៃ បន្ទាប់ពីតំកល់ទុក នូវលិខិតូបករណ៍សច្ចាប័ន ឬការអនុម័តយល់ព្រមដោយរដ្ឋភាគីទាំងអស់ដែលបានបោះឆ្នោតវិជ្ជមាននៅក្នុងសន្និសីទវិសោធនកម្ម ។

៧-ដើម្បីធានាប្រសិទ្ធិភាព និងការអនុវត្តន៏នៃសន្ធិសញ្ញានេះ ផ្នែកទី ១ និងទី ៣ នៃពិធីសារ និងឧបសម្ពន្ធ័ ១ និង ២ នៃពិធីសារត្រូវកែប្រែយោងទៅតាមកថាខ័ណ្ឌ ៨ ប្រសិនបើសំណើកែប្រែនោះ ទាក់ទងទៅនឹងបញ្ហារដ្ឋបាល ឬបច្ចេកទេស ។ បទបញ្ញត្តិ ទាំងឡាយផ្សេងៗទៀតនៃពិធីសារ និងឧបសម្ពន្ធ័នោះ មិនត្រូវកែប្រែយោងទៅតាមកថាខណ្ឌ ទី ៨ ឡើយ ។

៨-សំណើកែប្រែដូចមានចែងក្នុងកថាខ័ណ្ឌទី ៧ ត្រូវប្រព្រឹត្តិទៅស្របតាមនីតិវិធីដូចខាងក្រោម :

ក-អត្ថបទនៃសំណើកែប្រែត្រូវបញ្ជូនជាមួយពត៌មានចាំបាច់ទៅអគ្គនាយក ។ ពត៌មានបន្ថែមទៀតចំពោះការវាយតំលៃលើសំណើអាចផ្តល់ដោយរដ្ឋភាគី និងអគ្គនាយក ។ អគ្គនាយក

ជាបន្ទាន់តាមរយៈការចរចា ឬតាមមធ្យោបាយសន្តិភាពផ្សេងៗ តាមជំរើសរបស់ភាគីនោះរាប់បញ្ចូលទាំងការសុំជំនួយពីស្ថាប័ននានាក្នុងសន្ធិសញ្ញានេះ និងដោយយល់ព្រមគ្នាទៅវិញទៅមក បញ្ជូនករណីនេះ ទៅតុលាការអន្តរជាតិស្របតាមលក្ខន្តិកៈតុលាការអន្តរជាតិ ។ ភាគីដែលពាក់ព័ន្ធត្រូវផ្តល់ដំណឹងដល់ក្រុមប្រឹក្សាប្រតិបត្តិ អំពីសកម្មភាពដែលខ្លួនធ្វើនោះ ។

៣-ក្រុមប្រឹក្សាប្រតិបត្តិ អាចចូលរួមក្នុងការដោះស្រាយជំលោះ ដែលអាចកើតឡើងទាក់ទងទៅនឹងការអនុវត្តន៍ ឬការបកស្រាយសន្ធិសញ្ញានេះ ដោយមធ្យោបាយអ្វីក៏ដោយដែលក្រុមប្រឹក្សាប្រតិបត្តិយល់ឃើញថាសមស្រប រួមទាំងការជួយអោយភាគីជំលោះទាក់ទងដោះស្រាយជំលោះជាមួយគ្នា និងអំពាវនាវដល់រដ្ឋភាគីជំលោះអោយស្វែងរកដំណោះស្រាយតាមជំរើសផ្ទាល់ខ្លួនរបស់គេ ឬលើកយកបញ្ហានេះទៅពិភាក្សាក្នុងសន្និសីទ និងណែនាំពេលវេលាជាក់លាក់សំរាប់នីតិវិធីដោះស្រាយនេះ ។

៤-សន្និសីទ ពិចារណាលើបញ្ហា ដែលទាក់ទងទៅនឹងទំនាស់ ដែលលើកឡើងដោយរដ្ឋភាគី ឬក្រុមប្រឹក្សាប្រតិបត្តិ ។ នៅពេលដែលយល់ថាមានការចាំបាច់ សន្និសីទត្រូវបង្កើត ឬប្រគល់ឱ្យស្ថាប័នដែលពាក់ពន្ធ័ទៅនឹងកិច្ចការដោះស្រាយជំលោះស្របតាមមាត្រាទី ២ កថាខ័ណ្ឌទី ២៦ ញ ។

៥-អាស្រ័យនឹងការសំរេច ពីមហាសន្និបាតអង្គការសហប្រជាជាតិ សន្និសីទ និងក្រុមប្រឹក្សាប្រតិបត្តិមានអំណាចស្នើទៅតុលាការអន្តរជាតិ ដើម្បីផ្តល់នូវមតិណែនាំលើបញ្ហាច្បាប់ ដែលកើតក្នុងកម្មវត្ថុនៃសកម្មភាពរបស់អង្គការ ។ កិច្ចព្រមព្រៀងរវាងអង្គការនេះ និងអង្គការសហប្រជាជាតិ ត្រូវធ្វើនៅក្នុងគោលដៅដូចមាន ចែងក្នុងមាត្រា ទី ២ កថាខ័ណ្ឌ ៣៨ ជ ។

៦-មាត្រានេះ មិនមានការប៉ះពាល់ចំពោះមាត្រា ទី ៤ និង ទី ៥ ឡើយ ។

## មាត្រា ៧

## ការធ្វើវិសោធនកម្ម

១-ក្រោយពីការចូលជាធរមាននៃសន្ធិសញ្ញានេះ រដ្ឋភាគីអាចលើកសំណើ ដើម្បីធ្វើវិសោធនកម្មលើសន្ធិសញ្ញានេះ លើពិធីសារ ឬទៅនឹងឧបសម្ពន្ធ័នៃពិធីសារ ។ រាល់រដ្ឋភាគីអាចលើកសំណើដើម្បីធ្វើការផ្លាស់ប្តូរផងដែរ ដោយស្របតាមកថាខណ្ឌ័ទី ៧ លើពិធីសារ ឬឧបសម្ពន្ធ័ នៃ

ត្រូវជូនដំណឹងជាបន្ទាន់នូវសំណើ និងពត៌មានទាំងនោះទៅរដ្ឋភាគី ក្រុមប្រឹក្សាប្រតិបត្តិ និងរដ្ឋតំកល់ទុកសន្ធិសញ្ញា ។

ខ-ដោយមិនអោយយឺតជាង ៦០ ថ្ងៃ បន្ទាប់ពីទទួលសំណើ អគ្គនាយក ត្រូវវាយតំលៃលើសំណើ និងកំណត់ផលវិបាកនានាចំពោះបទបញ្ញត្តិទាំងឡាយ នៃសន្ធិសញ្ញានេះ ព្រមទាំងផ្តល់ពត៌មានទាំងនោះ ចំពោះរដ្ឋភាគីទាំងអស់ និងក្រុមប្រឹក្សាប្រតិបត្តិ ។

គ-ក្រុមប្រឹក្សាប្រតិបត្តិ និងពិនិត្យលើសំណើ ដោយឈរលើពត៌មានទាំងឡាយ ដែលមានរួមទាំងសំណើ ថាតើសំណើនេះ បំពេញតាមលក្ខខ័ណ្ឌចែងក្នុងកថាខ័ណ្ឌទី ៧ ដែរឬទេ ? ។ ក្រុមប្រឹក្សាប្រតិបត្តិនឹងធ្វើការបញ្ជាក់នូវអនុសាសន៏របស់ខ្លួន រួមជាមួយនិងការពន្យល់ដ៏សមស្របមួយ ចំពោះរដ្ឋភាគីទាំងអស់ ដើម្បីធ្វើការពិចារណាដោយមិនអោយយឺតជាង ៩០ ថ្ងៃ ។ រដ្ឋភាគីត្រូវឆ្លើយតបថាគួរទទួលអនុសាសន៏នេះ ក្នុងកំឡុងពេល ១០ ថ្ងៃ ។

ឃ-ប្រសិនបើ ក្រុមប្រឹក្សាប្រតិបត្តិណែនាំទៅរាល់រដ្ឋភាគីទាំងអស់ ថាសំណើនេះគួរត្រូវអនុម័តនោះ សំណើនេះត្រូវបានចាត់ទុកជាអនុម័ត ប្រសិនបើគ្មានរដ្ឋណាមួយជំទាស់ ក្នុងរយៈពេល ៣០ ថ្ងៃ បន្ទាប់ពីទទួលអនុសាសន៏នេះ ។ ប្រសិនបើក្រុមប្រឹក្សាប្រតិបត្តិ ណែនាំថាសំណើគួរត្រូវជំទាស់ សំណើនោះត្រូវបានចាត់ទុកជាជំទាស់ ប្រសិនបើគ្មានរដ្ឋភាគីណាបដិសេធទៅនឹងការជំទាស់ក្នុងកំឡុងពេល ៩០ ថ្ងៃ បន្ទាប់ពីទទួលអនុសាសន៏ ។

ង-ប្រសិនបើ អនុសាសន៏នៃក្រុមប្រឹក្សាប្រតិបត្តិ មិនបានទទួលការយល់ព្រមស្របតាមលក្ខខណ្ឌចែង ក្នុងកថាខ័ណ្ឌរង ( ឃ ) សេចក្តីសំរេចលើសំណើ ព្រមទាំងការបំពេញដែលតំរូវក្នុងកថាខ័ណ្ឌទី ៧ នឹងចាត់ទុកជាបញ្ហាសំខាន់ដោយសន្និសីទ ដែលត្រូវពិនិត្យនៅសម័យប្រជុំលើកក្រោយ ។

ច-អគ្គនាយក ត្រូវជូនដំណឹងទៅរដ្ឋភាគីទាំងអស់ និងរដ្ឋតំកល់ទុកសន្ធិសញ្ញានូវរាល់សេចក្តីសំរេច ក្នុងកថាខ័ណ្ឌនេះ ។

ឆ-ការកែតំរូវ ដែលបានអនុម័តតាមនីតិវិធីនេះ ត្រូវចូលជាធរមាន សំរាប់គ្រប់រដ្ឋភាគីទាំងអស់ ក្នុងរយៈពេល ១៨០ ថ្ងៃ បន្ទាប់ពីមានកាលបរិច្ឆេទជូនដំណឹង ពីសេចក្តីយល់ព្រមរបស់គេដោយអគ្គនាយក ប្រសិនបើពុំមានការណែនាំអោយកំណត់រយៈពេលផ្សេង ដោយក្រុមប្រឹក្សាប្រតិបត្តិ ឬត្រូវសំរេចដោយសន្និសីទ ។

# មាត្រា ៨

# ការពិនិត្យ សន្ធិសញ្ញាឡើងវិញ

១-ក្នុងរយៈពេល ១០ ឆ្នាំ បន្ទាប់ពីចូលជាធរមាននៃសន្ធិសញ្ញានេះ សន្និសីទរបស់រដ្ឋភាគីទាំងអស់ នឹងត្រូវរៀបចំពិនិត្យមើលឡើងវិញនូវការប្រតិបត្តិ និងធ្វើអោយមានប្រសិទ្ធភាព នៃសន្ធិសញ្ញានេះ លុះត្រាតែមានការសំរេចដោយមតិភាគច្រើននៃរដ្ឋជាភាគី ។ ដោយឈរលើទស្សនៈជាក់ច្បាស់របស់ខ្លួន នូវការសំរេចគោលបំណង និងគោលដៅដែលចែងក្នុងបុព្វកថា និងបទបញ្ញត្តិទាំងឡាយនៃសន្ធិសញ្ញា ។

ការពិនិត្យឡើងវិញនេះ នឹងត្រូវរាប់បញ្ចូលរាល់ការអភិវឌ្ឍន៍លើវិទ្យាសាស្ត្រ និងបច្ចេកទេស ដែលពាក់ព័ន្ធចំពោះសន្ធិសញ្ញានេះ ។ ផ្អែកលើមូលដ្ឋាននៃសំណើរបស់រដ្ឋភាគីណាមួយសន្និសីទស្តីពីការពិនិត្យឡើងវិញ នឹងពិចារណានូវការអនុញ្ញាតដល់លទ្ធភាពក្នុងការកំទេចចោលអាវុធនុយក្លេអ៊ែរក្រោមដី ក្នុងគោលបំណងដើម្បីសន្តិភាព ។ ប្រសិនបើ សន្និសីទស្តីពីការពិនិត្យសារឡើងវិញ សំរេចជាកុងសង់ស៊ុសដោយមតិឯកភាពរួម ដោយបានអនុញ្ញាតអោយមានការកំទេចចោលនុយក្លេអ៊ែរបែបនេះ ។ ហើយសន្និសីទត្រូវចាប់ផ្តើមការងារដោយគ្មានពេលកំណត់ ។ រួមជាមួយទស្សនៈណែនាំដ៏សមរម្យមួយដល់រដ្ឋភាគីទាំងឡាយ នូវការធ្វើវិសោធនកម្ម ចំពោះសន្ធិសញ្ញានេះ ដែលចៀសវាងផ្តល់ផលប្រយោជន៍យោធាក្នុងការផ្ទុះនុយក្លេអ៊ែរបែបនេះ ។ ការស្នើយោបល់ធ្វើវិសោធនកម្ម ត្រូវជូនដំណឹងដល់អគ្គនាយក ដោយរដ្ឋភាគីណាមួយ និងត្រូវអនុវត្តដោយផ្អែកទៅលើបទបញ្ញត្តិទាំងឡាយ នៃមាត្រា ៧ ។

២-ក្នុងចន្លោះរយៈពេល ១០ ឆ្នាំ បន្ទាប់ពីនេះ សន្និសីទស្តីពីការពិនិត្យឡើងវិញ អាចកោះប្រជុំក្នុងគោលដៅដដែល ប្រសិនបើសន្និសីទសំរេចថាបញ្ហានេះ ជាបញ្ហានីតិវិធីនៅក្នុងឆ្នាំមុនៗ ។ សន្និសីទនោះ អាចកោះប្រជុំ បន្ទាប់ពីចន្លោះពេលយ៉ាងតិចជាង ១០ ឆ្នាំ ប្រសិនបើមានការសំរេចដោយសន្និសីទថា ជាបញ្ហាសំខាន់ៗ ។

៣-ជាធម្មតាសន្និសីទ ស្តីពីការត្រួតពិនិត្យឡើងវិញ ត្រូវប្រព្រឹត្តិទៅភ្លាមៗ បន្ទាប់ពីការប្រជុំសាមញ្ញទៀងទាត់ប្រចាំឆ្នាំនៃសន្និសីទ ដូចបានចែង ក្នុងមាត្រា ២ ។

## មាត្រា ៩
## រយៈពេល និង ការដកខ្លួនចេញ

១-សន្ធិសញ្ញានេះ មានរយៈពេលពុំកំណត់ ។

២-រដ្ឋភាគីនីមួយៗ និងមានសិទ្ធិដកខ្លួនចេញពីសន្ធិសញ្ញានេះ ប្រសិនបើគេសំរេចថា មានទៅភាពមិនប្រក្រតី ដែលពាក់ពន្ធ័ទៅនឹងបញ្ហាជាគោលនៃសន្ធិសញ្ញានេះ ហើយនឹងធ្វើអោយប៉ះពាល់ដល់ផលប្រយោជន៍ជាចំបងរបស់ខ្លួន ក្នុងការអនុវត្តន៍អធិបតេយ្យភាពជាតិរបស់ខ្លួន ។

៣-ក្រុមប្រឹក្សាប្រតិបត្តិ នឹងផ្តល់ជាពត៌មានមុន ៦ ខែ ស្តីពីការដកខ្លួនចេញពីសន្ធិសញ្ញាទៅរដ្ឋភាគី នឹងមានប្រសិទ្ធភាពដោយផ្តល់សេចក្តីជូនដំណឹង ៦ ខែ ជាមុនដល់រដ្ឋភាគីផ្សេងៗទៅកន្លែងតំកល់ទុកសន្ធិសញ្ញា និងក្រុមប្រឹក្សាសន្តិសុខនៃអង្គការសហប្រជាជាតិ ។ ការជូនដំណឹងស្តីពីការដកខ្លួនចេញ ត្រូវរៀបចំនូវសេចក្តីថ្លែងការណ៍ពីព្រឹត្តិការណ៍សំខាន់ ឬព្រឹត្តិការណ៍ផ្សេងៗទៀត ដែលរដ្ឋភាគីចាត់ទុកថាប៉ះពាល់ដល់ផលប្រយោជន៍កំពូលរបស់រដ្ឋភាគី ។

## មាត្រា ១០
## ឋានៈ នៃពិធីសារ និង ឧបសម្ព័ន្ធ

ឧបសម្ព័ន្ធ និងពិធីសារនៃសន្ធិសញ្ញានេះ និងឧបសម្ព័ន្ធនៃពិធីសារ រាល់សេចក្តីយោងចំពោះសន្ធិសញ្ញានេះ រាប់បញ្ចូលទាំងឧបសម្ព័ន្ធនៃសន្ធិសញ្ញានេះ ពិធីសារ និងឧបសម្ព័ន្ធនៃពិធីសារ គឺជាផ្នែកមិនអាចផ្តាច់បាននៃសន្ធិសញ្ញានេះ ។

## មាត្រា ១១
## ការចុះហត្ថលេខា

សន្ធិសញ្ញានេះ នឹងត្រូវបើកចំហសំរាប់ការចុះហត្ថលេខាមុនពេលសន្ធិសញ្ញានេះចូលជាធរមាន។

## មាត្រា ១២
## សច្ចាប័ន

សន្ធិសញ្ញានេះ ត្រូវជាប្រធានបទ ក្នុងការផ្ដល់សច្ចាប័នដោយរដ្ឋចុះហត្ថលេខាទាំងឡាយ ស្រប ទៅតាមដំណើរការធម្មនុញ្ញនៃរដ្ឋនីមួយៗ ។

## មាត្រា ១៣
## ការចូលជាសមាជិកភាគី

រាល់រដ្ឋនីមួយៗ ដែលមិនបានចុះហត្ថលេខាលើសន្ធិសញ្ញានេះ មុនពេលសន្ធិសញ្ញានេះចូលជាធរមាន អាចចូលជាភាគីនៃសន្ធិសញ្ញានេះគ្រប់ពេលវេលា ។

## មាត្រា ១៤
## ការចូលជាធរមាន

១-សន្ធិសញ្ញានេះ ចូលជាធរមានក្នុងរយៈពេល ១៨០ ថ្ងៃ បន្ទាប់ពីថ្ងៃតំកល់ទុកលិខិតូបករណ៍សច្ចាប័នដោយរដ្ឋទាំងអស់ ដូចបានចែងក្នុងឧបសម្ព័ន្ធ ២ នៃសន្ធិសញ្ញានេះ ។ សន្ធិសញ្ញានេះ មិនត្រូវចូលជាធរមានមុនរយៈពេល ២ ឆ្នាំ បន្ទាប់ពីការបើកចំហសំរាប់ចុះហត្ថលេខាឡើយ ។

២-ប្រសិនបើ សន្ធិសញ្ញានេះមិនចូលជាធរមានក្នុងរយៈពេល ៣ ឆ្នាំ បន្ទាប់ថ្ងៃខួបគំរប់នៃការបើកចំហសំរាប់ចុះហត្ថលេខា រដ្ឋតំកល់ទុកសន្ធិសញ្ញានេះ ត្រូវកោះប្រជុំសន្និសីទរបស់រដ្ឋទាំងឡាយណា ដែលបានតំកល់លិខិតូបករណ៍នៃសច្ចាប័នតាមសំណើភាគច្រើននៃរដ្ឋទាំងអស់នោះ ។

សន្និសីទនោះ នឹងពិនិត្យអំពីវិសាលភាពនៃលក្ខខណ្ឌ ដែលត្រូវបំពេញ ដូចចែងក្នុងកថាខណ្ឌ ១ នឹងត្រូវពិចារណា និងសំរេចដោយកុងសង់ស៊ុស ( Consensus ) ពីវិធានការសមស្របតាមច្បាប់អន្តរជាតិ ដើម្បីបង្កើននីតិវិធីសច្ចាប័នក្នុងបំណងសំរួលការចូលជាធរមាននៃសន្ធិសញ្ញានេះអោយបានរហ័ស ។

៣-ប្រសិនបើ ពុំមានការសំរេចផ្សេងពីនេះ ដោយសន្និសីទដូចបានចែងក្នុងកថាខ័ណ្ឌ ២ ឬ ដោយសន្និសីទផ្សេងទៀត ដំណើរការនេះត្រូវអនុវត្តម្តងទៀត បន្ទាប់ពីឆ្នាំខួបនៃការបើកចំហសំរាប់ចុះហត្ថលេខារហូតដល់ការចូលជាធរមាននៃសន្ធិសញ្ញា ។

៤-គ្រប់រដ្ឋហត្ថលេខី ត្រូវបានអញ្ជើញចូលរួមក្នុងសន្និសីទដោយផ្អែកទៅតាមកថាខ័ណ្ឌ ២ និង ជាអ្នកអង្កេតការណ៍នៅក្នុងសន្និសីទបន្តបន្ទាប់ទៀត ដូចចែងនៅក្នុងកថាខ័ណ្ឌ ៣ ។

៥-ចំពោះរដ្ឋដែលផ្តល់លិខិតូបករណ៍សច្ចាប័ន ឬការភ្ជាប់ជាភាគីនៃសន្ធិសញ្ញាក្រោយការចូលជាធរមាន នៃសន្ធិសញ្ញានេះ ត្រូវចូលជាធរមានក្នុងថ្ងៃទី ៣០ បន្ទាប់ពីថ្ងៃតំកល់លិខិតូបករណ៍សច្ចាប័ន ឬការភ្ជាប់ជាភាគីនោះ ។

## មាត្រា ១៥

## ការបដិសេធ

រដ្ឋមិនអាចដាក់លក្ខខណ្ឌមិនអនុវត្តចំពោះមាត្រាទាំងឡាយ និងឧបសម្ព័ន្ធនៃសន្ធិសញ្ញានេះឡើយ ។ រដ្ឋមិនអាចដាក់លក្ខខណ្ឌមិនអនុវត្តណា ដែលផ្ទុយនឹងកម្មវត្ថុ និងគោលដៅនៃសន្ធិសញ្ញានេះ ចំពោះបទបញ្ញត្តិទាំងឡាយនៃពិធីសារសន្ធិសញ្ញានេះ និងឧបសម្ព័ន្ធនៃពិធីសារបានឡើយ ។

## មាត្រា ១៦

## ការតំកល់ទុក .

១-អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវតំកល់ទុកសន្ធិសញ្ញានេះ នឹងត្រូវទទួលហត្ថលេខា លិខិតូបករណ៍សច្ចាប័ន និងលិខិតូបករណ៍នៃការភ្ជាប់ជាភាគី ។

២-ភាគីតំកល់ទុកត្រូវជូនដំណឹងភ្លាមដល់រដ្ឋហត្ថលេខីទាំងអស់ និងរដ្ឋភ្ជាប់ជាភាគីពីកាលបរិច្ឆេទចុះហត្ថលេខានីមួយៗ ថ្ងៃតំកល់ទុកនៃលិខិតូបករណ៍ សច្ចាប័ន ឬការភ្ជាប់ជាភាគី ថ្ងៃចូលជាធរមាន ថ្ងៃធ្វើវិសោធនកម្ម ឬការកែប្រែនានា និងថ្ងៃទទួលនូវពត៌មានផ្សេងៗ ។

៣-ភាគីតំកល់ទុកត្រូវបញ្ជូនលិខិតចំលង ដោយមានការបញ្ជាក់ត្រឹមត្រូវទៅកាន់រដ្ឋាភិបាល នៃរដ្ឋហត្ថលេខី និងរដ្ឋភ្ជាប់ជាភាគី ។

៤-សន្ធិសញ្ញានេះ ត្រូវចុះបញ្ជីដោយភាគីតំកល់ទុក យោងទៅតាមមាត្រា ទី ១០២ នៃធម្មនុញ្ញអង្គការសហប្រជាជាតិ ។

## មាត្រា ១៧

## អត្ថបទ មានតំលៃត្រឹមត្រូវ

សន្ធិសញ្ញានេះ មានជាភាសា អារ៉ាប់ ចិន អង់គ្លេស បារាំង រុស្ស៊ី និងអេស្ប៉ាញ ។ រាល់អត្ថបទមានតំលៃស្មើៗគ្នា ។ អត្ថបទទាំងនេះ ត្រូវតំកល់ទុកនៅអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

# ច្បាប់

# ស្តីពី

# អគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា